# មន្ទីរព័ត៌មានខេត្តប៉ៃលិន

## លេខ០១៥

## ព្រឹត្តិប័ត្រព័ត៌មាន ប្រចាំខែវិច្ឆិកា ឆ្នាំ២០២១



រដ្ឋបាលខេត្តប៉ៃលិន ប្រារព្ធខួបអនុស្សាវរីយ៍ លើកទី៦៨នៃទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា១៩៥៣-៩វិច្ឆិកា២០២១ និងទិវាកំណើតកងយោធពលខេមរភូមិន្ទក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍ អ៊ី ឈាន រដ្ឋលេខាធិការក្រសួងការពារជាតិ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តប៉ៃលិន។



លោកជំទាវ បាន ស្រីមុំ អភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការសាខាកាកបាទក្រហមកម្ពុជាខេត្តប៉ៃលិន បានអញ្ជើញចុះសំណេះសំណាលសួរសុខទុក្ខ និងនាំយកអំណោយដ៏របស់សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុនរ៉ានី ហ៊ុនសែន ចែកជូនដល់ប្រជាពលរដ្ឋមានជីវភាពខ្វះខាតដែលរងផលប៉ះពាល់ដោយសារវិបត្តិជម្ងឺកូវីដ-១៩ ចំនួន៧៥គ្រួសារ មកពីសង្កាត់ទាំង៤ក្នុងក្រុងប៉ៃលិន

អាស័យដ្ឋានៈ ភូមិប៉ាហ៊ីត្បូង សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន
Tel: 088 8777773, 077 877979 ,096 225 11 33

# មន្ទីរព័ត៌មានខេត្តប៉ៃលិន

លេខ០១៥
ខែវិច្ឆិកា ឆ្នាំ២០២១

## មាតិកា


- អភិបាលខេត្តប៉ៃលិន អញ្ជើញបើកយុទ្ធនាការ ចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជូនកុមារអាយុ ៥ឆ្នាំ ....................៤
- អាជ្ញាធរមីនកម្ពុជាកម្ពុជា បានអំពាវនាវឲ្យអាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធ បន្តចូលរួមផ្សព្វផ្សាយការអប់រំយល់ដឹងអំពីមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមឲ្យបានទូលំទូលាយ ....................៦
- លោកជំទាវ បាន ស្រីមុំ អញ្ជើញចុះសួរសុខទុក្ខ និង ចូលរួមរំលែកទុក្ខជាមួយប្អូនស្រី ថោ ចាន់ទីន ដែលកំពុងសម្រាកព្យាបាលជំងឺកូវីដ-១៩ នៅមណ្ឌលខេត្តប៉ៃលិន ....................៩
- ព្រះពុទ្ធសាសនាបានចូលរួមចំណែកយ៉ាងសកម្មលើការងារមនុស្សធម៌ ការបណ្ដុះធនធានមនុស្ស និងលើកកម្ពស់សីលធម៌សង្គម ....................១១
- អភិបាលខេត្តប៉ៃលិន ដឹកនាំកិច្ចប្រជុំត្រួតពិនិត្យ ការរៀបចំខួបអនុស្សាវរីយ៍លើកទី៦៨ នៃទិវាឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ....................១៤
- លោកយាយ លោកតាចាស់ជរាគ្មានទីពឹងក្នុងខេត្តប៉ៃលិន ទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែពីមូលនិធិចាស់ជរារបស់លោកជំទាវ បាន ស្រីមុំ អ៊ី ឈាន ....................១៦
- ប្រជាពលរដ្ឋមានជីវភាពខ្វះខាតនៅក្រុងប៉ៃលិន ចំនួន ៧៥គ្រួសារ ទទួលអំណោយពីសម្ដេចតេជោ ហ៊ុន សែន និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ....................១៨
- រដ្ឋបាលខេត្តប៉ៃលិន ប្រារព្ធមីទ្ទិញអបអរសាទរខួបអនុស្សាវរីយ៍លើកទី៦៨ នៃទិវាបុណ្យឯករាជ្យជាតិ ....................២១
- ភាស៊ីផ្សារទាំង៤ នៅទូទាំងខេត្តប៉ៃលិនត្រូវបានដាក់ប្រជុំដេញថ្លៃនៅមន្ទីរសេដ្ឋកិច្ចនឹងហិរញ្ញវត្ថុខេត្ត ....................២៤
- ឯកឧត្តម អ៊ី ឈាន អញ្ជើញពន្លត់ទៀនជ័យ ក្រោយអុជបំភ្លឺរយៈពេល ៣ថ្ងៃ នៃពិធីបុណ្យឯករាជ្យជាតិលើកទី៦៨ ....................២៦
- រដ្ឋបាលខេត្តប៉ៃលិន រៀបចំសួនផ្កាចម្រុះពណ៌ នៅតំបន់ទឹកធ្លាក់អូរតាវ៉ៅដើម្បីទាក់ទាញទេសចរណ៍មកកំសាន្ត ខេត្តប៉ៃលិន ....................២៩
- ល្អាងភ្នំព្រះឥន្ទលក់លតជាសក្ដានុពលទេសចរថ្មីរបស់ខេត្តប៉ៃលិន ....................៣១

- ❖ លោក ជំទាវ បាន ស្រីមុំ ប្រជុំដោះស្រាយទំនាស់ដីធ្លីរវាង លោក នុន ស៊ីនឿន និង ប្រជាពលរដ្ឋចំនួន ៨គ្រួសារ ស្ថិតនៅភូមិបឹងព្រលិត ....................៣២
- ❖ អភិបាលខេត្តប៉ៃលិន ពិនិត្យមើលការដ្ឋានស្ថាបនាផ្លូវបេតុងអាមេ ឡើងទៅកាន់ រម្មណីយដ្ឋានធម្មជាតិទឹកធ្លាក់អូរតាវ៉ៅ ដើម្បីផ្តល់សេវាឱ្យកាន់តែងាយស្រួលក្នុង ការធ្វើដំណើររបស់ភ្ញៀវទេសចរណ៍ ....................៣៤
- ❖ អភិបាលខេត្តប៉ៃលិន ពិនិត្យមើលការដ្ឋានស្ថាបនាផ្លូវក្រាលកៅស៊ូ ប្រភេទ DBST ២ខ្សែរ ប្រវែង ៥៤គីឡូម៉ែត្រ ....................៣៧
- ❖ ក្រុមការងារគណបក្សប្រជាជនកម្ពុជាចុះជួយសង្កាត់ទួលល្វារៀបចំការបោះឆ្នោតជ្រើស រើសបេក្ខជនសម្រាប់ឈរឈ្មោះជាក្រុមប្រឹក្សាសង្កាត់ សម្រាប់ការប្រឡងប្រជែងក្នុងការ បោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ នាឆ្នាំ២០២២ខាងមុខ ....................៣៩
- ❖ អភិបាលខេត្តប៉ៃលិន កាត់ស្រោមវិញ្ញាសាប្រឡងជ្រើសរើសក្របខ័ណ្ឌមន្រ្តីរាជការស៊ីវិល បម្រើការនៅរដ្ឋបាលខេត្ត សម្រាប់ឆ្នាំ២០២១ ....................៤១
- ❖ សាខាកាកបាទក្រហមកម្ពុជាខេត្តប៉ៃលិន សហការជាមួយមន្ទីរសុខាភិបាល និងមន្ទីរព័ត៌មានខេត្តប៉ៃលិន បានផ្សព្វផ្សាយស្តីពីការបង្ការទប់ស្កាត់ជំងឺកូវីដ-19 តាមវិទ្យុជាតិ FM 90.5 Mhz ខេត្តប៉ៃលិន ....................៤៣
- ❖ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តប៉ៃលិន ប្រារព្ធទិវាជាតិលើកកម្ពស់អនាម័យជនបទ ១៣ វិច្ឆិកា លើកទី១២ ក្រោមប្រធានបទ (គុណតម្លៃនៃការអនុវត្តន៍អនាម័យនិងការសំអាត ) ....................៤៤
- ❖ រដ្ឋបាលខេត្តប៉ៃលិនជួបសំណេះសំណាលជាមួយអង្គការ សាម៉ារីតាន់ភឺស ស្តីពីអនាម័យ អប់រំ និងទឹកស្អាត ដើម្បីលើកកម្ពស់អនាម័យ នឹងទឹកស្អាតតាមសាលារៀនព្រមទាំង សហគមន៍អោយមានភាពល្អប្រសើរក្នុងឆ្នាំ ២០២២ ....................៤៧

## អភិបាលខេត្តប៉ៃលិន អញ្ជើញបើកយុទ្ធនាការ ចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជូនកុមារអាយុ ៥ឆ្នាំ







ប៉ៃលិនៈ នៅមន្ទីរពេទ្យបង្អែកខេត្តប៉ៃលិន នាព្រឹកថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២១ លោកជំទាវ បាន ស្រីមុំ អភិបាលខេត្តប៉ៃលិន និងក្រុមការងារ បានអញ្ជើញប្រកាសបើកយុទ្ធនាការថ្មីមួយទៀត គឺការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជូនដល់កុមារអាយុ ៥ឆ្នាំ ដែលត្រូវបានគេចាត់ទុកថា ជាយុទ្ធនាការប្រកបដោយការទទួលខុសត្រូវខ្ពស់ ក្នុងការការពារអាយុជីវិតកុមារពីជំងឺកាចសាហាវកូវីដ-១៩ និងការបើកអោយដំណើរការបង្រៀន និងរៀនឡើងវិញ សម្រាប់សិស្សមត្តេយ្យសិក្សា។



លោកជំទាវ បាន ស្រីមុំ អភិបាលខេត្តប៉ៃលិន បានមានប្រសាសន៍លើកឡើងថាៈ សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី បានយកចិត្តទុកដាក់ខ្ពស់ចំពោះការចាក់វ៉ាក់សាំងបង្ការជម្ងឺកូវីដ-១៩ ជូនដល់ប្រជាពលរដ្ឋ រួមទាំងកុមារផងដែរ ដើម្បីឱ្យសិស្សានុសិស្សបានចូលរៀនដោយគ្មានការភ័យខ្លាច ព្រោះកន្លងមករាជរដ្ឋាភិបាលកម្ពុជា បានបើកយុទ្ធនាការចាក់វ៉ាក់សាំង ដល់យុវវ័យ ចាប់ពីអាយុ ១២ឆ្នាំ ដល់ ក្រោម ១៨ឆ្នាំ និងចាប់ពីអាយុ ៦ឆ្នាំ ទៅ ១២ឆ្នាំ ហើយពេលនេះ បន្តចាក់វ៉ាក់សាំងដល់កុមារអាយុ ៥ឆ្នាំ ដែលតម្រូវសម្រាប់សិស្សមត្តេយ្យសិក្សា បឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ ហើយកំពុងត្រៀមសម្រាប់កុមារអាយុក្រោម ៥ឆ្នាំ ដែលនេះចាត់ទុកជាជំហានបន្ទាប់មួយទៀត។



លោកជំទាវអភិបាលខេត្ត ក៏បានមានប្រសាសន៍កោតសរសើរ ចំពោះប្រជាពលរដ្ឋ ដែលមានស្មារតីចូលរួមមកទទួលការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដែលមានចំនួនយ៉ាងច្រើនផុលផុស ទាំងនេះបានបង្ហាញឱ្យឃើញពីជំនឿជឿជាក់របស់ប្រជាពលរដ្ឋយើង មកលើការដឹកនាំរបស់សម្តេចតេជោ ហ៊ុន សែន ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ដែលសម្តេចបានខិតខំស្វះស្វែងរកវ៉ាក់សាំង




ដើម្បីផ្តល់ជូនប្រជាពលរដ្ឋដោយមិនគិតថ្លៃ និងមិនមានការរើសអើង រួមទាំងកុមារ និងយុវជនផងដែរ ក្នុងគោលដៅរួមគ្នាប្រយុទ្ធប្រឆាំងនិងបង្ការទប់ស្កាត់ការចម្លងរីករាលដាលនៃជំងឺកូវីដ-១៩ ។






ក្នុងឱកាសនោះផងដែរ លោកជំទាវ បាន ស្រីមុំ ក៏បានមានប្រសាសន៍ក្រើនរំលឹកដល់បងប្អូនប្រជាពលរដ្ឋគ្រប់គ្នា បើទោះបីបានចាក់វ៉ាក់សាំងការពាររួចរាល់ហើយក្តី ក៏កុំភ្លេចខ្លួន និងមានការធ្វេសប្រហែស ហើយត្រូវបន្តចូលរួមអនុវត្តឱ្យបានខ្ជាប់ខ្ជួន នូវវិធានការនានារបស់ក្រសួងសុខាភិបាល និងវិធានការណ៍ការពារ ៣.ការពារ






៣.កុំ របស់សម្តេចតេជោ ហ៊ុនសែន ដើម្បីកាត់ផ្តាច់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងសហគមន៍របស់យើង។



សូមបញ្ជាក់ថា៖ យុទ្ធនាការចាក់វ៉ាក់សាំងបង្ការជម្ងឺកូវីដ-១៩ ដល់កុមារ អាយុ ៥ឆ្នាំនេះ គឺចាប់ផ្តើមពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២១ តទៅ ដោយពេលព្រឹកចាប់ពីម៉ោង ៨៖០០ នាទីព្រឹក ដល់ម៉ោង ១១៖០០ នាទី ហើយពេលរសៀលចាប់ពីម៉ោង ២៖០០ នាទីរសៀល ដល់ម៉ោង ៥៖០០ នាទីល្ងាច នៅគោលដៅចំនួន ០៣ (១-មន្ទីរពេទ្យបង្អែកខេត្តប៉ៃលិន ២-មណ្ឌលសុខភាពផ្សារព្រំ និង៣-មណ្ឌលសុខភាពភ្នំស្តង់)៕

# អាជ្ញាធរមីនកម្ពុជាកម្ពុជា បានអំពាវនាវឲ្យអាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធ បន្តចូលរួមផ្សព្វផ្សាយការអប់រំយល់ដឹង អំពីមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមឲ្យបានទូលំទូលាយ



ប៉ៃលិនៈ ឯកឧត្តមទេសរដ្ឋមន្ត្រី លី ធុជ អនុប្រធានទី១ អាជ្ញាធរមីនកម្ពុជា បានអំពាវនាវឲ្យមន្ត្រីជំនាញ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវបន្តចូលរួមយកចិត្តទុកដាក់ផ្សព្វផ្សាយការអប់រំយល់អំពីមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម ឲ្យបានទូលំទូលាយនៅគ្រប់ជំនួបសំណេះសំណាល និងគ្រប់វេទិកាទាំងអស់ ជាមួយបងប្អូនប្រជាពលរដ្ឋ ជាពិសេសត្រូវធ្វើសេចក្ដីរាយការណ៍ជាប្រចាំជូនដល់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្ត-ក្រុង/ស្រុក ឃុំ/សង្កាត់ អំពីស្ថានភាពគ្រោះថ្នាក់ និងបញ្ហាមីននៅតាមមូលដ្ឋាន ដើម្បីមានការណែនាំ និងមានចំណាត់ការបន្ថែម។

ការអំពាវនាវរបស់ឯកឧត្តមទេសរដ្ឋមន្ត្រីបែបនេះ នៅក្នុងពិធីតម្លើងផ្ទាំងប៉ាណូផ្សព្វផ្សាយការអប់រំការយល់ដឹងអំពីមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម នៅព្រឹកថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២១ តាមបណ្ដោយព្រំដែនកម្ពុជាថៃ - ស្ថិតក្នុងឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន ដោយមានការអញ្ជើញចូលរួមផងដែរពីសំណាក់ លោក ហៃម ឬទ្ធី អភិបាលរងខេត្តប៉ៃលិន តំណាងដ៏ខ្ពង់ខ្ពស់លោកជំទាវបាន ស្រីមុំ អភិបាលនៃគណៈអភិបាលខេត្តប៉ៃលិន អាជ្ញាធរដែនដី មន្ត្រីជំនាញពាក់ព័ន្ធ និងប្រជាពលរដ្ឋ។







ឯកឧត្តម លី ធុជ ក៏បានមានប្រសាសន៍ជម្រុញឲ្យមន្ត្រីនគរបាលប៉ុស្តិ៍តាមបណ្តោយព្រំដែន បន្តជួយផ្សព្វផ្សាយជូនចំពោះបងប្អូនពលករ មិនត្រូវប្រថុយប្រថានចូលក្នុងតំបន់ដែល មិនស្គាល់ទីតាំងភូមិសាស្ត្រច្បាស់លាស់ក្នុងបំណងណាមួយដូចជា៖ ការប្រើប្រាស់ដី



រុករកអនុផលព្រៃឈើ ធ្វើដំណើរឆ្លងកាត់ មិនត្រូវប៉ះពាល់គ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមជាដាច់ខាត ហើយត្រូវរាយការណ៍មកអាជ្ញាធរមូលដ្ឋាន មេឃុំ មេភូមិ ប្រតិបត្តិករបោសសម្អាតមីន ឬសមត្ថកិច្ចនគរបាលជាបន្ទាន់ នៅពេលបានឃើញ បានដឹងពីកន្លែងមានមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមនេះ។





ក្នុងឱកាសនោះផងដែរ ឯកឧត្តមអនុប្រធានទី១ អាជ្ញាធរមីនកម្ពុជា ក៏បានប្រសាសន៍នាំមកនូវបណ្តាំផ្ញើសាកសួរសុខទុក្ខរបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី ជាប្រធានអាជ្ញាធរមីនកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ចំពោះបងប្អូនប្រជាពលរដ្ឋ និងប្រតិបត្តិករដោះ



មីនទាំងអស់នៅក្នុងខេត្តប៉ៃលិន ហើយត្រូវបន្តយកចិត្តទុកដាក់ខ្ពស់ចំពោះសុខសុវត្ថិភាព ដោយត្រូវមានប្រុងប្រយ័ត្ន និងត្រូវស្ថិតនៅចៀសឲ្យឆ្ងាយពីយុទ្ធភណ្ឌមិនទាន់ផ្ទុះ និងតំបន់សង្ស័យថាមានគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ ដែលនៅសេសសល់ពីសម័យសង្គ្រាម។







សូមបញ្ជាក់ថា៖ គិតត្រឹមខែកញ្ញា ឆ្នាំ២០២១ ខេត្តប៉ៃលិន មានផ្ទៃដីបោសសម្អាតរួចរាល់ចំនួន ៧៨០៤៦,៩៨៧, ម៉ែត្រក្រឡា (ប្រមាណ ៧៩ គីឡូម៉ែត្រក្រឡា) រកឃើញ និងកំទេចចោលមីនប្រឆាំងមនុស្សបាន



ចំនួន ៥៤៦១៧, គ្រាប់ មីនគោនចំនួន ៤០៤ គ្រាប់ និងសំណល់ជាតិផ្ទុះពីសង្គ្រាមចំនួន ២៣៤២២, គ្រាប់ ចំណែកផ្ទៃដីដែលនៅសល់ ចំនួន ២៥ ៧៦៣,៥២៣, ម៉ែត្រក្រឡា (ប្រមាណ ២៥.៥ គីឡូម៉ែត្រក្រឡា)



(៤៣០ស្មើនឹងចម្ការមីនចំនួន )ដែលបានសបន្សល់ទុកគ្រាប់មីន យុទ្ធភណ្ឌមិនទាន់ផ្ទុះដោយសារភ្លើងសង្គ្រាមគ្រប់ទីកន្លែង ហើយអាជ្ញាធរមីនកម្ពុជា នឹងខិតខំប្រឹងប្រែងបោសសម្អាតមីនអោយអស់តាមផែនការគ្រោងទុកផងដែរ៕





# លោកជំទាវ បាន ស្រីមុំ អញ្ជើញចុះសួរសុខទុក្ខ និង ចូលរួមរំលែកទុក្ខជាមួយប្អូនស្រី ថោ ចាន់ទីន ដែលកំពុងសម្រាកព្យាបាលជំងឺកូវីដ-១៩ នៅមណ្ឌលខេត្តប៉ៃលិន





ថ្ងៃទី០២ ខែវិច្ឆិការ ឆ្នាំ២០២១ លោកជំទាវ បាន ស្រីមុំ អភិបាលខេត្តប៉ៃលិន រួមដំណើរដោយឯកឧត្តម សៅ សារ៉ាត់ អ្នកតំណាងរាស្ត្រមណ្ឌលប៉ៃលិន ឯកឧត្តម អភិបាលរង លោកស្នងការនគរបាលខេត្ត លោកគ្រូពេទ្យ អ្នកគ្រូពេទ្យ បានអញ្ជើញចុះសួរសុខទុក្ខ និង ចូលរួមរំលែកទុក្ខជាមួយប្អូនស្រី ថោ ចាន់ទីន រួមទាំងស្វាមី, មានទីលំនៅស្រុកកំរៀង ខេត្តបាត់ដំបង ដែលមានកូនប្រុសស្លាប់ដោយសារជំងឺកូវីដ-១៩ ហើយពួកគាត់ទាំងពីនាក់ក៏ កំពុងសម្រាកព្យាបាលជំងឺកូវីដ-១៩ នៅមណ្ឌលព្យាបាលជំងឺកូវីដ-១៩ នៅក្នុងខេត្តប៉ៃលិន ។



លោកជំទាវ បាន ស្រីមុំ អភិបាលខេត្តប៉ៃលិន បានមានប្រសាសន៍សំដែងការសោកស្តាយជាខ្លាំងហើយ ក៏បានខិតខំប្រឹងប្រែងជួយប្អូនស្រី អស់ពីសម្ថភាព ក្រោយបានដឹង និងយល់សាច់រឿងការពិត នៃមូលហេតុ ដែរធ្វើអោយមានការភាន់ច្រឡំយល់ខុសទាំងសងខាង ។ លោកជំទាវបានមានប្រសាសន៍ថា៖ ពេលនេះការពិត



បានដឹង និង យល់ច្បាស់ជ្រះស្រលះ យើងទាំងអស់គ្នាមិនបានប្រកាន់ខឹង ឬ ដាក់ទោសកំហុសដល់ភាគីខាងណាឡើយ គឺខុសទាំងអស់គ្នា ឈ្នះទាំងអស់គ្នា ។ លោកជំទាវ បានសំដែងការអរគុណដល់ក្រុមគ្រូពេទ្យទាំងអស់ ដែលបានតស៊ូប្រឹងប្រែងទាំងថ្ងៃទាំងយប់ សឹងតែរកពេលសំរាកពុំបាន អស់រយៈពេលជិត ២ឆ្នាំមកនេះ ទោះបី ទទួលរងការចោទប្រកាន់ ពីមហាជន ទទួលកាស្តីបន្ទោសពីថ្នាក់ដឹកនាំ ទាំងយុត្តិធម៌ អយុត្តិធម៌ ស្តាល់គ្រប់

រសជាតិ ផ្អែមល្វីងជូរចត់បែបណាក៏ដោយ លោកគ្រូ-អ្នកគ្រូ ក្រុមការងារយើងទាំងអស់ទទួលយកដោយ ស្នាមញញឹម ព្រោះយើងជាមន្ត្រីបំរើរាស្ត្រ រួមសុខរួមទុក្ខជាមួយគ្នា ទោះស្ថិតក្នុងកាលៈទេសៈ លំបាក យ៉ាងណាក៏ដោយ



យើងជាអ្នកអនុវត្តន៍ផ្ទាល់តែងតែមានទាំងខុសមានទាំងត្រូវ គ្រាន់ភាពត្រឹមត្រូវមានច្រើនជាង ភាពខុសនោះគឺខុសដោយ អចេតនាតែប៉ុណ្ណោះ ។ លោកជំទាវ បានបន្តថា បើសិនជាបងប្អូនមិនចង់ខុស មានតែអង្គុយចាំថា អង្គុយចាំរិះគន់ អង្គុយចាំមើល អង្គុយចាំចាប់កំហុស



ដោយមិនដឹងរឿងពិតពីខាងក្រោយ ហើយមិនចាំបាច់ធ្វើអ្វីទាំងអស់ទើបមិនចេះខុស។ ដូច្នេះក្នុងនាមយើងជាមន្ត្រីស្អាតស្អំ ត្រូវបន្តដំណើរតស៊ូទៅមុខទៀតជាមួយគ្នា ព្រោះយើងមានសម្តេចតេជោ ហ៊ុន សែន ជាថ្នាក់ដឹកនាំដ៏ល្អ ជាថ្នាក់ដឹកនាំគំរូ ជាថ្នាក់ដឹកនាំពោរពេញដោយព្រហ្មវិហារធម៌ ថ្នាក់ដឹកនាំដែល នៅរួមសុខរួមទុក្ខ ជាមួយ



ប្រជាពលរដ្ឋគ្រប់កាលៈទេសៈ។ ដូច្នេះយើងជាកូនជាចៅសម្តេចត្រូវតែរួមគ្នា ខិតខំប្រឹងប្រែងដោយកិត្តិយស តស៊ូបន្តទៅមុខទៀត ដើម្បីប្រយោជន៍ជាតិ និង ដើម្បីសុខភាពប្រជាជនយើង ។



ក្នុងឱកាសនោះដែរលោកជំទាវ បាន ស្រីមុំ អភិបាលខេត្តប៉ៃលិន ក៏បានជួយឧបត្ថម្ភថវិកាចំនួន ២ លានរៀល ដល់ប្អូនស្រី ថោ ចាន់ទីន និងស្វាមី ដើម្បីជួយសម្រួលដល់ជីវភាពគ្រួសារ៕ (អត្ថបទៈ វួច ពឿន AKP ប៉ៃលិន)



# ព្រះពុទ្ធសាសនាបានចូលរួមចំណែកយ៉ាងសកម្មលើការងារមនុស្សធម៌ ការបណ្តុះធនធានមនុស្ស និងលើកកម្ពស់សីលធម៌សង្គម



ប៉ៃលិន៖ លោក ឃ្លោក នួយ អភិបាលរងខេត្តប៉ៃលិន បានមានប្រសាសន៍លើកឡើងថា៖ វិស័យ ព្រះពុទ្ធសាសនា នាពេលបច្ចុប្បន្នបានចូលរួមចំណែកយ៉ាងសកម្មទាំងផ្នែកការងារមនុស្សធម៌ និងលើក កម្ពស់ សីលធម៌ ចរិយាធម៌ ដល់កុលបុត្រកុលធីតា និងបច្ឆាជនជំនាន់ក្រោយ ឲ្យចេះសាងអំពើល្អ តាមគន្លងប្រពៃណី ព្រះពុទ្ធសាសនា ក្នុងគោលបំណងកាត់បន្ថយ ការខុសឆ្គង ក្នុងច្បាប់រដ្ឋ និងប្រពៃណីជាតិយើង ដើម្បីពង្រឹង ទាំងចំណេះដឹង ទាំងជំនាញ និងបទពិសោធន៍ រួមចំណែកដល់ការអភិវឌ្ឍជាតិ ក្រោមការដឹកនាំប្រកបដោយកិត្តិបណ្ឌិតរបស់សម្តេចតេជោ ហ៊ុន សែន ប្រមុខរាជរដ្ឋាភិបាលកម្ពុជា។

លោកអភិបាលរងខេត្ត បានប្រសាសន៍មានបែបនេះ នៅក្នុងឱកាសអញ្ជើញជាអធិបតីតំណាងដ៏ខ្ពង់ខ្ពស់របស់លោកជំទាវ បាន ស្រីមុំ អភិបាលខេត្តប៉ៃលិន ក្នុងពិធីប្រកាសព្រះភិក្ខុ ទូច ម៉ាច ជាព្រះចៅអធិការស្តីទី វត្តភ្នំនាគសំរិទ្ធិជ័យ ហៅវត្តអូរទឹកភ្លាវ ស្ថិតក្នុងភូមិអូរទឹកភ្លៀវ ឃុំអូរអណ្តូង ស្រុកសាលាក្រៅ ខេត្តប៉ៃលិន នារសៀលថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១ ដោយមានវត្តមាននិមន្តចូលរួមពីសំណាក់ ព្រះគ្រូសន្តិមហារតន៍មុនី សាន់ លី  ព្រះរាជាគណៈថ្នាក់កិត្តិយស និងជាព្រះធម្មរណើរតន៍ព្រះមេគណគណៈធម្មយុត្តិកនិកាយខេត្តប៉ៃលិន ព្រមទាំងថ្នាក់ដឹកនាំ គ្រប់ជាន់ថ្នាក់ និងពុទ្ធបរិស័ទចំណុះជើងវត្តយ៉ាងច្រើនកុះករផងដែរ។







លោក ឃ្លោក នួយ បានមានប្រសាសន៍រំលឹកថា៖ ការបាត់បង់ស្ទើរតែសាបសូន្យទៅហើយនូវវិស័យ សាសនា និងហេដ្ឋារចនាសម្ព័ន្ធនានា នៅក្នុងរបបកម្ពុជា ប្រជាធិបតេយ្យ តែដោយគុណបុណ្យស្មារតី ០២ ធ្នូ ១៩៧៨ និងថ្ងៃជ័យជនះ ៧ មករា ១៩៧៩ ជាពិសេស គោលនយោបាយឈ្នះៗ របស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី បានធ្វើឲ្យប្រទេសជាតិទាំងមូល មានសុខ



សន្តិភាពពេញលេញ និងធ្វើឲ្យមានការអភិវឌ្ឍន៍រីកចម្រើន ទាំងវិស័យពុទ្ធចក្រ និង អាណាចក្រ ហើយរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា បានកំណត់ ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ ហើយមានសេរីភាពសាសនា ដោយ មិនប្រកាន់គណៈ មហានិកាយ គណៈធម្មយុត្តិកនិកាយ ឬ ឥស្លាមសាសនា និង សាសនាកាតូលិកឡើយ។

លោកអភិបាលរងខេត្ត បានមានប្រសាសន៍ បញ្ជាក់ថា៖ ព្រះពុទ្ធសាសនា បានចូលរួមចំណែកអភិវឌ្ឍន៍ សង្គមយ៉ាងសំខាន់ ផ្អែកពុទ្ធិដល់ពលរដ្ឋឲ្យគោរពវិន័យ ច្បាប់ និងព្រាន់ប្រដៅមនុស្ស ឲ្យដើរតាមផ្លូវល្អ ប្រព្រឹត្តតែ អំពើល្អ រស់នៅដោយសុខុដមរនា នៅក្នុងសង្គមគ្រួសារ សហគមន៍ ដែលមិនមានអំពើហិង្សា ប្រកបដោយ សន្តិ ភាព យុត្តិធម៌ ដូច្នេះ«ព្រះពុទ្ធសាសនាមិនត្រឹមតែបានធ្វើ ឱ្យបងប្អូន ប្រជាពលរដ្ឋ យើងបានរួមរស់ជាមួយគ្នាដោយ



សុខសាន្តខាងផ្លូវស្មារតីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានរួម ចំណែក យ៉ាងសំខាន់ នៅក្នុងការពង្រឹងសណ្តាប់ធ្នាប់ សុខសន្តិភាព ស្ថិរភាពសង្គម ការអភិវឌ្ឍលើគ្រប់វិស័យ និងថែរក្សាការពារអត្តសញ្ញាណជាតិទៀតផង»។

ព្រះគ្រូសន្តិមហារតន៍មុនី សាន់ លី ព្រះរាជាគ ណៈថ្នាក់កិត្តិយស និងជាព្រះធម្មមរណីរតន៍ព្រះមេគណ គណៈធម្មយុត្តិកនិកាយខេត្តប៉ៃលិន បានមានសង្ឃដីកា ផ្តល់នូវពុទ្ធឱវាទប្រគេនជូនដល់ព្រះភិក្ខុសង្ឃ ពុទ្ធបរិស័ទ ទាំងឡាយ យកទៅគោរពបដិបត្តិ ទៅតាមគន្លងនៃវិន័យ



ព្រះសម្មាសម្ពុទ្ធ ដែលជាព្រះ បរម្យគ្រូនៃយើង បានចងក្រងជាគម្ពី បិដក ឲ្យគោរពទៅតាមព្រះធម៌វិន័យរបស់ព្រះពុទ្ធសាសនា ហើយវត្តអារាមជាទីជំរក អប់រំរិយាធម៌ ដល់ពុទ្ធបរិស័ទ យុវជន ដែលជាទំពាំង ស្នងឫស្សី និងជាឱកាសល្អក្នុងការ រួបរួមគ្នា ដើម្បីថែរក្សាការពារ សេចក្តីសុខសាន្តរបស់សង្គមជាតិ ដោយប្រកាន់យកព្រះពុទ្ធឱវាទ



ជាប្រទីបបំភ្លឺផ្លូវ ក្នុងការអប់រំសីលធម៌ ចរិយាធម៌ សេចក្តីថ្លៃថ្នូរ សមនឹងទស្សនៈដែលថា ព្រះពុទ្ធសាសនាជាកម្លាំងដឹកនាំចរិយាធម៌សង្គម ក្នុងការលុបបំបាត់អំពើហិង្សាសង្គម។

នៅក្នុងឱកាសនោះដែរ ព្រះគ្រូសន្តិមហារតន៍មុនី សាន់ លី ក៏បានផ្តាំផ្ញើដល់អាជ្ញាធរមូលដ្ឋាន ព្រះ សង្ឃ និងអាចារ្យគណៈកម្មការវត្ត ជាពិសេសព្រះភិក្ខុ ទូច ម៉ាច ចៅអធិការវត្តស្តីទីថ្មី ត្រូវរម្ងាប់អធិករណ៍នានា និងសហការគ្រប់គ្រង គរុភណ្ឌសង្ឃ មានដីធ្លីវត្តអារាម ព្រមទាំងអប់រំពុទ្ធសាសនិកជន ឲ្យរៀនសូត្របដិបត្តិធម៌ និងវិន័យ





មានបិដកជាគោល ហើយរួមសាមគ្គីរវាងព្រះសង្ឃ និងពុទ្ធបរិស័ទ ដោយធ្វើការពង្រីកនូវវិស័យពុទ្ធកៈសិក្សា និងអភិវឌ្ឍន៍ អភិរក្សនូវវប្បធម៌ ប្រពៃណីទំនៀមទំលាប់របស់ជាតិផងដែរ។



បើតាមការបញ្ជាក់របស់លោក សំ សារឿន ប្រធានមន្ទីរធម្មការ និងសាសនាខេត្តប៉ៃលិន បានអោយដឹងថា៖ បច្ចុប្បន្ននៅក្នុងខេត្តប៉ៃលិន មានវត្តអារ៉ាម ចំនួន ៣២វត្ត ក្នុងនោះ វត្តធម្មយុត្តិកនិកាយមានចំនួន ៦វត្តផងដែរ៕



# អភិបាលខេត្តប៉ៃលិន ដឹកនាំកិច្ចប្រជុំត្រួតពិនិត្យ ការរៀបចំខួបអនុស្សាវរីយ៍លើកទី៦៨ នៃទិវាឯករាជ្យជាតិ ៩ វិច្ឆិកា និង ទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ






ប៉ៃលិន៖ ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១ លោកជំទាវ បាន ស្រីមុំ អភិបាលនៃគណៈអភិបាលខេត្តប៉ៃលិន បានដឹកនាំកិច្ចប្រជុំត្រួតពិនិត្យ ការរៀបចំមេទ្ទិងខួបអនុស្សាវរីយ៍លើកទី៦៨ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០២១ ដើម្បីអបអរសាទរ ចំពោះជ័យជំនះជាប្រវត្តិសាស្ត្រ ដែលកម្ពុជាទាមទារបានមកវិញនូវឯករាជ្យទាំងស្រុងពីអាណានិគមនិយមបារាំង។



លោកជំទាវ បាន ស្រីមុំ អភិបាលខេត្តប៉ៃលិន បានមានប្រសាសន៍លើកឡើងថា៖ ការប្រារព្ធខួបអនុស្សាវរីយ៍លើកទី៦៨ នៃទិវាបុណ្យឯករាជ្យជាតិ និងទិវាខួបកំណើតនៃកងយោធពលខេមភូមិមិន្ទ គឺពិតជាមានសារៈសំខាន់ណាស់ ក្នុងការរំលឹកដល់សមិទ្ធិផល និងជាស្នាមព្រះហស្ថដ៏មហាថ្លៃថ្លារបស់ព្រះមហាវីរៈក្សត្រ ព្រះបាទសម្តេចព្រះនរោត្តមសីហនុ ព្រះបរមរតនកោដ្ឋ ដែលព្រះអង្គដណ្តើមបានទាំងស្រុងនូវឯករាជ្យជាតិពីអាណានិគមនិយមបារាំង នាថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ហើយបានបង្កើតឡើងនូវកងយុទ្ធពលខេមរភូមិន្ទដ៏ក្លាហានរបស់ប្រជាជាតិខ្មែរ និងបានកសាងអភិវឌ្ឍន៍ប្រទេសកម្ពុជាអោយមានការរីកចំរើនលើគ្រប់វិស័យ។

លោកជំទាវអភិបាលខេត្ត បានមានប្រសាសន៍ណែនាំដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងកងកំលាំងទាំងបីប្រភេទ ត្រូវយកចិត្តទុកដាក់ និងទទួលខុសត្រូវខ្ពស់ ក្នុងការអនុវត្តផែនការការងារដែលបានដាក់ចេញ អោយមាន





ប្រសិទ្ធភាពខ្ពស់ មានសណ្តាប់ធ្នាប់ មានភាពអធិកអធម ឧត្តុង្គឧត្តម សំរាប់ការប្រារព្ធមេទ្ទីងរំលឹកខួបអនុស្សាវរីយ៍ លើកទី៦៨ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា ១៩៥៣-៩ វិច្ឆិកា ២០២១ និងទិវាថ្ងៃកំណើតកងយុទ្ធពលខេមរភូមិន្ទ នាពេលខាងមុខ ពោរពេញដោយស្នាមញញឹម និងភាពក្លៀវក្លាប្រកបដោយមោទនភាពជាតិ។



នៅក្នុងឱកាសនោះផងដែរ លោកជំទាវ បាន ស្រីមុំ បានមានប្រសាសន៍ស្នើឱ្យមន្ទីរសុខាភិបាលខេត្ត ធ្វើការរៀបចំនូវសម្ភារៈដែលតម្រូវការចាំបាច់ និងមានរថយន្តសង្គ្រោះ ដើម្បីត្រៀមនៅពេលមានបងប្អូនប្រជាពលរដ្ឋដែលបានចូលរួម និងមន្ត្រីរាជការកងកម្លាំងប្រដាប់អាវុធមានបញ្ហាអីកើតឡើង ត្រូវជួយសង្គ្រោះឱ្យទាន់ពេលវេលា

និងត្រូវដាក់ម៉ាស៊ីនវាស់កំដៅ រួមជាមួយទឹកអាកុល ឬ ដែល ព្រមទាំងម៉ាសផងដែរ ដោយធ្វើយ៉ាងណាចូលរួមកាត់បន្ថយហានិភ័យពីការចម្លងរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងសហគមន៍ ជាពិសេសរួមគ្នាអនុវត្តឲ្យបានខ្ជាប់ខ្ជួន នូវវិធានការការពាររបស់ប្រមុខរាជរដ្ឋាភិបាលសម្តេចតេជោ ហ៊ុន សែន គឺ៣ការពារ ៣កុំ ។



សូមបញ្ជាក់ថា៖ គម្រោងនៃការរៀបចំពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៦៨ នៃទិវាឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទឆ្នាំ២០២១នេះ លោកជំទាវ បាន ស្រីមុំ អភិបាល នៃគណៈអភិបាលខេត្តប៉ៃលិន បានចេញសេចក្តីណែនាំដល់មន្ទីរអង្គភាព អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ត្រូវរៀបចំចាត់ចែងការងារតាំងលម្អភ្លើង ចងបដាពាក្យស្លោក ទង់ សាសនា ព្រះមហាក្សត្រ នៅតាមទីតាំងសហគ្រាស ឯកជននិងទីសាធារណៈ ហើយណែនាំឱ្យប្រជាជនចងទង់ជាតិនៅតាមផ្ទះជាដើម ដោយឡែកកងកំលាំងប្រដាប់អាវុធគ្រប់ប្រភេទត្រូវពង្រឹងការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈជូនពលរដ្ឋ និងភ្ញៀវទេសចរដែលមកកំសាន្តនៅខេត្តប៉ៃលិន អោយបានល្អប្រសើរ។



# លោកយាយ លោកតាចាស់ជរាគ្មានទីពឹងក្នុងខេត្តប៉ៃលិន ទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែ ពីមូលនិធិចាស់ជរារបស់ លោកជំទាវ ប្លាន ស្រីមុំ អ៊ី ឈាន



ប៉ៃលិន៖ ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១ ឯកឧត្តម ហុក សុផល ក្នុងនាមលោកជំទាវ បាន ស្រីមុំ ប្រធានមូលនីធិចាស់ជរា និងជាអភិបាលខេត្តប៉ៃលិន បានដឹកនាំ យុវជន សសយក យុវជនកាកបាទក្រហម និង ក្រុមការងារមូលនីធិ អញ្ជើញសំណេះសំណាលសួរសុខទុក្ខជាមួយលោកតា លោកតាចាស់ជរាគ្មានទីពឹង និងមានជីវភាពខ្វះខាតទូទាំងខេត្តប៉ៃលិន ដែលមកទទួលប្រាក់ឧបត្ថម្ភប្រចាំខែ ពីក្រុមការងាររបស់មូលនិធិនៅតាមគោលដៅទាំង៣។



ឯកឧត្តម ហុក សុផល បានមានប្រសាសន៍នាំមកនូវបណ្ដាំផ្ញើសាកសួរសុខទុក្ខពីសំណាក់ឯកឧត្តម អ៊ី ឈាន ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តប៉ៃលិន និងលោកជំទាវ បាន ស្រីមុំ ប្រធានមូលនីធិ ជូនដល់លោកយាយ លោកតាចាស់ជរាទាំងអស់ ដែលជានិច្ចកាលឯកឧត្តម និងលោកជំទាវ តែងតែគិតគូពីសុខទុក្ខរបស់ប្រជាពលរដ្ឋគ្រប់រូប គ្រប់កាលៈទេសៈ និងគ្រប់ទីកន្លែងនៅទូទាំងខេត្តប៉ៃលិន។



ឯកឧត្តម បានមានប្រសាសន៍លើកឡើងថា៖ មូលនិធិនេះបានបង្កើតឡើងក្នុងគោលបំណង និងទិសដៅជួយដល់លោកយាយ លោកតាចាស់ជរាគ្មានទីពឹង មានជីវភាពខ្សត់ខ្សោយ និងមានអាយុចាប់ពី៧០ឆ្នាំឡើងទៅ ដែលពុំមានលទ្ធភាពអាចចេញទៅប្រកបមុខរបរដើម្បីចិញ្ចឹមជីវិតបាន ក៏ដូចជាការជួយលើកកំពស់កម្រិត

ជីវភាព និងបំប៉នថែរទាំសុខភាពលោកយាយលោកតា ដោយមិនប្រកាន់បក្សពួក និងនិន្នាការនយោបាយឡើយ ព្រោះមនុស្សចាស់ គឺមានគុណបំណាច់ធំធេងណាស់ ក្នុងការជួយអប់រំ ប្រៀនប្រដៅ ដល់កូនចៅជំនាន់ក្រោយៗ ឲ្យប្រព្រឹត្តិតែ អំពើល្អ។



ក្នុងឱកាសនោះដែរឯកឧត្តម ហុក សុផល ក៏បានមានប្រសាសន៍អំពាវនាវដល់ប្រជាពលរដ្ឋទាំងអស់ សូមចូលរួមប្រយុទ្ធប្រឆាំង បង្ការទប់ស្កាត់ និងការពារការឆ្លងរីករាលដាល នៃជំងឺកូវីដ-១៩ ដោយត្រូវអនុវត្តន៍តាមការណែនាំរបស់ក្រសួងសុខាភិបាល និងចូលរួមគោរពអនុវត្តន៍នូវវិធានចាំបាច់នានារបស់រាជរដ្ឋាភិបាល ជាពិសេសត្រូវរួមគ្នាអនុវត្តឱ្យបានម៉ឺងម៉ាត់នូវវិធានការការពាររបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី គឺ ៣ការពារ ៣កុំ។






សូមបញ្ជាក់ថា៖ ដើម្បីសម្រួលដល់ការធ្វើដំណើររបស់លោកយាយ លោកតា ក្រុមការងារមូលនិធិត្រូវបានបែងចែកជា ៣ក្រុម គឺក្រុមទី១ បើកផ្តល់ជូនលោកយាយ



លោកតានៅទីស្នាក់ការសាខាកាកបាទក្រហមខេត្តប៉ៃលិន, ក្រុមទី២ នៅសាលាឃុំអូរអណ្តូង និងក្រុមទី៣ នៅសាលាឃុំស្ទឹងត្រង់ ដោយមូលនិធិ បានបើកផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែ ដល់លោកយាយ លោកតា ចាស់ជរា ចំនួន ៦២នាក់ ដោយក្នុងម្នាក់ៗទទួលបានថវិកាចំនួន ១០ម៉ឺនរៀល៕





# ប្រជាពលរដ្ឋមានជីវភាពខ្វះខាតនៅក្រុងប៉ៃលិន ចំនួន ៧៥គ្រួសារ ទទួលអំណោយពីសម្ដេចតេជោ ហ៊ុន សែន និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត






ប៉ៃលិន៖ ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២១ លោកជំទាវ បាន ស្រីមុំ អភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការសាខាកាកបាទក្រហមកម្ពុជាខេត្តប៉ៃលិន អមដំណើរដោយថ្នាក់ដឹកនាំ និងសមាជិក កិត្តិយសសាខា, គណៈកម្មាធិការសាខា អនុសាខា, អាជ្ញាធរមូលដ្ឋាន, យុវជនកាកបាទក្រហមខេត្ត និងយុវជនសហភាពសហព័ន្ធ យុវជនកម្ពុជាខេត្ត ព្រមទាំងក្រុមការងារ បានអញ្ជើញចុះសំណេះសំណាលសួរសុខទុក្ខ និងនាំយកអំណោយដ៏ថ្លៃថ្លារបស់សម្ដេចតេជោ ហ៊ុន សែន និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន មកចែកជូនដល់ប្រជាពលរដ្ឋមានជីវភាពខ្វះខាត ដែលរងផលប៉ះពាល់ ដោយសារវិបត្តិជម្ងឺកូវីដ-១៩ ចំនួន ៧៥គ្រួសារ មកពីសង្កាត់ទាំង៤ ក្នុងក្រុងប៉ៃលិន។



លោកជំទាវ បាន ស្រីមុំ ប្រធានគណៈកម្មាធិការសាខាកាកបាទក្រហមកម្ពុជាខេត្តប៉ៃលិន ក៏បាននាំមកនូវប្រសាសន៍ផ្ដាំផ្ញើសួរសុខទុក្ខ និងក្ដីនឹករលឹក អាណិតអាសូរក្រៃលែងពីសំណាក់ សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា ដែលសម្ដេចទាំងទ្វេរ តែងតែគិតគូពីសុខទុក្ខរបស់ប្រជាពលរដ្ឋងាយរងគ្រោះ



និងរងគ្រោះ ដោយគ្រោះមហន្តរាយ និងឧបទ្ទវហេតុផ្សេងៗ នៅទូទាំងប្រទេសគ្រប់ពេលវេលា ដោយមិនមានការរើសអើង វណ្ណៈ ជាតិសាសន៍ ពណ៌សម្បុរ ឬនិន្នាការនយោបាយអ្វីឡើយ ជាពិសេសមិនបណ្ដោយឱ្យពលរដ្ឋ

ណាម្នាក់ស្លាប់ដោយអត់បាយ មិនបានដឹង និងមិនបាន ជួយដោះស្រាយនោះទេ។



លោកជំទាវប្រធានគណៈកម្មាធិការសាខា បាន ប្រសាសន៍ឱ្យដឹងថា៖ ជាក់ស្តែងកន្លងមក សាខាកាក បាទក្រហមកម្ពុជាខេត្តប៉ៃលិន បានជម្រុញគ្រប់ សកម្មភាពការងារមនុស្សធម៌ ឱ្យអនុវត្តន៍ទៅដោយរលូន




និងមានប្រសិទ្ធភាពខ្ពស់ ដោយប្រកាន់ភ្ជាប់ នូវគោល ការណ៍គ្រឹះទាំង ០៧ប្រកា របស់ចលនាកាកបាទក្រហម កម្ពុជា ក្នុងការឆ្លើយតបបានទាន់ពេលវេលា ចំពោះ ជន រងគ្រោះ និងជនងាយរងគ្រោះ ព្រមទាំងបានផ្តល់ជា



សម្ភារៈ គ្រឿងឧបភោគបរិភោគ និងថវិកាមួយចំនួន ដល់ ប្រជាពលរដ្ឋដែលរងគ្រោះដោយសារឧបទ្ទវហេតុផ្សេងៗ ដូចជា៖ ខ្យល់កន្ត្រាក់ គ្រោះរាំងស្ងួត ទឹកជំនន់ គ្រោះអគ្គី ភ័យ គ្រោះថ្នាក់ចរាចរណ៍ ពលរដ្ឋមានជីវភាពខ្វះខាត គ្រួសារជនពិការ កុមារកំព្រា អ្នករស់នៅជាមួយមេរោគអេ ដស៍ ចាស់ជរាគ្មានទីពឹង និងគ្រួសារសពខ្វះខាត ជាដើម ជាពិសេសបានចូលរួមយ៉ាងសកម្ម ក្នុងការទប់ស្កាត់ការ ចម្លងរីករាលដាលនៃជម្ងឺកូវីដ-១៩។



នៅក្នុងឱកាសនោះផងដែរ លោកជំទាវ បាន ស្រី មុំ ក៏បានមានប្រសាសន៍ផ្តាំផ្ញើដល់បងប្អូនប្រជាពលរដ្ឋ ទាំងអស់ សូមយកចិត្តទុកដាក់ទៅលើបញ្ហាសុខភាព ដោយត្រូវរក្សាអនាម័យក្នុងការរស់នៅជាប្រចាំ ដូចជា៖ លាងដៃនឹងសាប៊ូ ហូបទឹកឆ្អិន និងដេកក្នុងមុងជានិច្ច ដើម្បីជាសវាងការកើតមានជំងឺតម្កាត់ផ្សេងៗ ជាពិសេស ជម៉ឺកូវីដ-១៩ ដែលយើងត្រូវរួមគ្នាប្រយុទ្ធប្រឆាំង បង្ការទប់ ស្កាត់ ការពារការឆ្លងរីករាលដាល នៃជំងឺកូវីដ-១៩ នៅ



ក្នុងសហគមន៍ ហើយត្រូវរួមគ្នាអនុវត្តឱ្យបានម៉ឺងម៉ាត់នូវវិធានការការពាររបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី គឺ ៣ការពារ ៣កុំ ហើយបើបងប្អូនមានបញ្ហាសុខភាព ឬករណីសង្ស័យ សូមប្រញ៉ាប់ប្រញាល់មកកាន់មន្ទីរពេទ្យបង្អែកខេត្ត ដើម្បីអោយក្រុមគ្រូពេទ្យជំនាញ ធ្វើការពិនិត្យសុខភាព ឬធ្វើសំណាក និងទទួលការព្យាបាលបានទាន់ពេលវេលា។



ជាការឆ្លើយតប បងប្អូនប្រជាពលរដ្ឋ បានសម្តែងនូវទឹកចិត្តរំភើប និងសប្បាយរីករាយឥតឧបមា ចំពោះសម្តេចទាំងទ្វេរ និងសាខាកាកបាទក្រហមកម្ពុជាខេត្តប៉ៃលិន ក្រោមការដឹកនាំរបស់លោកជំទាវ បាន ស្រីមុំ ជាប្រធានសាខា ដែលបានចុះជួយសម្រាលទុក្ខលំបាករបស់ពួកគាត់ ហើយសូមគោរពជូនពរ និងបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិក្នុងលោក ជួយប្រោះព្រំថែរក្សាផ្តល់សិរីសួស្តី ជ័យមង្គលវិបុលសុខ ដ៏ប្រសើរថ្លៃថ្លានិង ទទួលបាននូវជោគជ័យគ្រប់ភារកិច្ច





ព្រមទាំងបានសមប្រកបដោយពុទ្ធពរដ៏ប្រសើរថ្លៃថ្លា ទាំងបួនប្រការ គឺ អាយុ វណ្ណៈសុខៈ ពលៈ ជានិច្ចនិរន្តរ៍កុំបីឃ្លៀងឃ្លាតឡើយ។



សូមបញ្ជាក់ថា៖ អំណោយដែលផ្តល់ជូនដល់ប្រជាពលរដ្ឋមានជីវភាពខ្វះខាត ទាំង ៧៥គ្រួសារ ដោយក្នុងមួយគ្រួសារៗទទួលបាន៖ អង្ករ ៥០គីឡូ ត្រីខ ១យួរ ទឹកស៊ីអ៊ីវ ១យួរ មី ១កេស ទឹកបរិសុទ្ធ ១កេស  ឃីដ ១ (កន្ទេល ១, មុង ១, ភួយ ១, ក្រម៉ា ១) និងថវិកាមួយចំនួនផងដែរ៕



# រដ្ឋបាលខេត្តប៉ៃលិន ប្រារព្ធមីទ្ទិញអបអរសាទរខួបអនុស្សាវរីយ៍លើកទី៦៨ នៃទិវាបុណ្យឯករាជ្យជាតិ







ប៉ៃលិន៖ ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២១ រដ្ឋបាលខេត្តប៉ៃលិន បានប្រារព្ធខួបលើកទី៦៨ នៃទិវាបុណ្យឯករាជជាតិ៩ វិច្ឆិកា ១៩៥៣ ២០២១វិច្ឆិកា ៩-និងទិវាកំណើតកងយោធពលខេមរភូមិន្ទ ដែលបានតស៊ូយ៉ាងជោគជ័យ ដណ្តើមឯករាជ្យចេញផុតពីនឹមត្រួតត្រារបស់អាណានិគមនិយមបារាំង ដែលពិធីនេះស្ថិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមនាយឧត្តមសេនីយ៍ អ៊ី ឈាន  រដ្ឋលេខាធិការ ក្រសួងការពារជាតិ និងជាប្រធានក្រុមការងារ រាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តប៉ៃលិន  ព្រម



ទាំងមានការអញ្ជើញចូលរួមពីសំណាក់ លោកជំទាវ បានស្រីមុំ អភិបាលខេត្ត ឯកឧត្តម សៅ សារ៉ាត់ អ្នកតំណាងរាស្ត្រមណ្ឌលប៉ៃលិន និងឯកឧត្តម ជា ចាន់ឌីន ប្រធានក្រុមប្រឹក្សាខេត្តផងដែរ។

ស្ថិតក្នុងឱកាសដ៏ថ្លៃថ្លានោះ ឯកឧត្តមនាយឧត្តមសេនីយ៍ អ៊ី ឈាន  រដ្ឋលេខាធិការក្រសួងការពារជាតិ និងជាប្រធាន ក្រុមការងារ រាជរដ្ឋាភិបាល  ចុះជួយមូលដ្ឋានខេត្តប៉ៃលិន  បានមានប្រសាសន៍លើកឡើងថា៖ ខួបអនុស្សាវរីយ៍ នៃទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកានេះ គឺនៅទូ



ទាំងប្រទេសកម្ពុជា តែងតែប្រារព្ធធ្វើជារៀងរាល់ឆ្នាំ ព្រោះជាទិវាប្រវត្តិសាស្ត្រដ៏រុងរឿងដែលកម្លាំងមហាសាមគ្គីរបស់ប្រជាជាតិទាំងមូល ដណ្តើមបានទាំងស្រុងមកវិញពីអាណានិគមនិយមបារាំងនាឆ្នាំ១៩៥៣ នូវឯករាជ្យពិតប្រាកដ ក្រោមព្រះរាជបូជនីកិច្ចដ៏ថ្លៃថ្លានៃព្រះបរមរតន

កោដ្ឋ ព្រះករុណា ព្រះបាទ សម្តេច ព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិនៃយើងទាំងអស់គ្នា។



ឯកឧត្តមប្រធានក្រុមការងារ បានមានប្រសាសន៍គូសបញ្ជាក់ថាៈ រាជរដ្ឋាភិបាលកម្ពុជា ដែលដឹកនាំដោយ សម្តេចតេជោ ហ៊ុន សែន ជានាយករដ្ឋមន្ត្រី ក្រោមម្លប់របស់ព្រះមហាក្សត្រកម្ពុជា តែងតែដង្ហែរតាមព្រះរាជគំរិះ



ដ៏ថ្លៃថ្លាជាពៀងរហូតមក ជាពិសេសដោយសារការខិតខំប្រឹងប្រែងយ៉ាងខ្លាំង របស់ប្រមុខរាជរដ្ឋាភិបាល បានធ្វើឲ្យសង្គមជាតិទាំងមូល មានសុខសន្តិភាព និងមានការអភិវឌ្ឍន៍រីកចំរើនលើគ្រប់វិស័យ។





នៅក្នុងឱកាសនោះផងដែរ ឯកឧត្តម អ៊ី ឈាន បានប្រសាសន៍លើកឡើងថាៈ ការរំលឹកខួបអនុស្សាវរីយ៍ដែលជាទិវាប្រវត្តិសាស្រ្តដ៏រុងរឿង បានប្រព្រឹត្តទៅពេលជាមួយ នឹងទិវាកំណើតកងយោធពលខេមរភូមិន្ទ ក្នុងស្មារតីចងចាំជានិច្ចមិនអាចបំភ្លេចបាន នូវគុណូបការៈដ៏



ថ្លៃថ្លារបស់ វីរយុទ្ធជនយុទ្ធនារី និងប្រជាពលរដ្ឋនៅគ្រប់ទិសទី ដែលបានពុះពារប្រយុទ្ធតស៊ូធ្វើពលិកម្ម អាយុជីវិតយ៉ាងអង់អាចក្លាហានបំផុត ដើម្បីសង្គ្រោះជាតិ មាតុភូមិពីរបបប្រល័យពូជសាសន៍ ពីភ្នក់ភ្លើងសង្គ្រាមគ្រោះកាចចង្រៃផ្សេងៗ ព្រមទាំងបានរួមចំណែកយ៉ាងធំធេង ក្នុងការការពារទឹកដី អធិបតេយ្យ សេរីភាព សន្តិភាព និងវិបុលភាពជាតិ នៃព្រះរាជាណាចក្រកម្ពុជា៕

















# ភាស៊ីផ្សារទាំង៤ នៅទូទាំងខេត្តប៉ៃលិនត្រូវបានដាក់ប្រជុំដេញថ្លៃនៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត





(ប៉ៃលិន)៖ ព្រឹកថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១ នៅមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្តប៉ៃលិន មានបើកកិច្ចប្រជុំដេញថ្លៃភាស៊ីផ្សារទាំង៤ នៅទូទាំងខេត្តប៉ៃលិន សំរាប់ឆ្នាំ២០២២ រួមមានផ្សារសាមគ្គី ហៅផ្សារប៉ាហុី ផ្សារប៉ាងរលឹម ផ្សារព្រំថ្មីនិង ផ្សារសាលាក្រៅ ដែលកិច្ចប្រជុំដេញថ្លៃនេះបានធ្វើឡើងក្រោមអធិបតីភាពឯលោក ចេង ញ៉ាន់ អភិបាលរងខេត្តប៉ៃលិន និងមានការអញ្ជើញចូលរួមពីលោក-លោកស្រី នាយក នាយករងទីចាត់ការហិរញ្ញវត្ថុសាលាខេត្ត លោកអភិបាលក្រុង/ស្រុក លោកប្រធាន អនុប្រធានមន្ទីរ លោកមេឃុំ/ចៅសង្កាត់ ម្ចាស់ផ្សារ និងអាជីវករអ្នកដេញថ្លៃជាច្រើននាក់ទៀតផងដែរ។



លោក ឃឹម សួរ តំណាងក្រសួងសេដ្ឋកិច្ចនឹងហិរញ្ញវត្ថុ បានមានប្រសាសន៍ថា៖ ការកំណត់តម្លៃភាស៊ីផ្សារនៅទូទាំងខេត្តប៉ៃលិនសម្រាប់ឆ្នាំ២០២២នេះ មាន៖ ទី១/តូបលក់ទំនិញគ្រប់ប្រភេទក្នុង១តូប តម្លៃ៥០០រៀល ក្នុងមួយថ្ងៃ ។ ទី២/រានលក់ទំនិញគ្រប់ប្រភេទ ១រាន តម្លៃ៥០០រៀល ក្នុងមួយថ្ងៃ។ ទី៣/ផ្ញើរកង់គ្រប់ប្រភេទ ១គ្រឿង តម្លៃ២០០រៀល ក្នុងមួយលើក។ ទី៤/ផ្ញើរម៉ូតូគ្រប់ប្រភេទ ១គ្រឿង តម្លៃ៥០០រៀល ក្នុង១លើក។ ទី៥/ម្ចាស់ឆ័ត្រ ១កន្លែង តម្លៃ៣០០រៀលក្នុងមួយថ្ងៃ។ ទី៦/រយន្តផ្ទេរទំនិញ



ក្នុងផ្សារ ១គ្រឿង តម្លៃ១០០០រៀល ១លើក។ ទី៧/ផ្ញើររថយន្តគ្រប់ប្រភេទ ១គ្រឿង តម្លៃ១០០០រៀល ក្នុង១លើក។ ទី៨/តូប ឬរាន ដែលមានទំហំធំជាង៤ ម៉ែត្រការ៉េ ថែម ១ម៉ែត្រការ៉េ ១០០រៀលក្នុងមួយថ្ងៃ។

លោក ចេង ញ៉ាន់ អភិបាលរងខេត្តប៉ៃលិនបានមានប្រសាសន៍លើកឡើងថា៖ កិច្ចប្រជុំពិភាក្សាគ្នារវាង

គណៈកម្មាធិការផ្សារទាំង៤ក្នុងខេត្តប៉ៃលិន នឹងអ្នកដេញថ្លៃ ភាស៊ីផ្សារ និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ជារៀងរាល់មួយឆ្នាំម្តង ដើម្បីធ្វើការដេញថ្លៃភាស៊ីផ្សារអោយបានត្រឹមត្រូវ និងស្របតាមច្បាប់របស់រដ្ឋ សំដៅការរកចំណូល



ជូនរដ្ឋ ក៏ដូចជាការបំរើសេវាកម្មទីផ្សារជូនប្រជាពលរដ្ឋអាជីវករ អោយបានសមស្រប មិនអោយមានការគេងប្រវ័ញ្ច គៀបសង្កត់នោះឡើយ។ លោកបានមានប្រសាសន៍បន្តថា ទាំងម្ចាស់ផ្សារ នឹងអ្នកដេញថ្លៃភាស៊ី ក៏ត្រូវស្តាប់ការណែនាំរបស់មន្ទីរសេដ្ឋកិច្ច នឹងហិរញ្ញវត្ថុដែល



ជាអង្គភាពជំនាញ និងត្រូវអនុវត្តតាមការណែនាំ និងកិច្ចកុងត្រាភាស៊ីផ្សារដែលបានដេញថ្លៃរួចមកនេះ អោយមានប្រសិទ្ធភាពខ្ពស់។ ទន្ទឹមនឹងនេះ អ្នកដេញថ្លៃភាស៊ីផ្សារទាំងអស់ ត្រូវសហការជាមួយម្ចាស់ផ្សារ នឹងក្រុមអាជីវករទាំងអស់ ធ្វើការអនាម័យ និងកែលំអ សោភ័ណភាពផ្សារអោយបានស្អាតជាប្រចាំ ដើម្បីទាក់ទាញភ្ញៀវចូលមកទិញទំនិញ ប្រើប្រាស់សេវាកម្មរបស់ខ្លួន។



សូមបញ្ជាក់ថា៖ ផ្សារទូទាំងខេត្តប៉ៃលិនមានចំនួន៤ ផ្សារ គឺផ្សារសាមគ្គី ហៅផ្សារប៉ាហ៊ី ផ្សារប៉ាងរលឹម ផ្សារព្រំថ្មី និងផ្សារសាលាក្រៅ។ ឆ្លងតាមការដេញថ្លៃរយៈពេលពេញមួយព្រឹករួចមក ជាលទ្ធផល គឺលោកមាស វុធ ទទួលបានសិទ្ធិគ្រប់គ្រងយកភាស៊ីនៅផ្សារសាមគ្គី ,





លោកជាង នីសា បានទទួលសិទ្ធគ្រប់គ្រង យកភាស៊ីលើផ្សារប៉ាងរលឹម, លោកគឹម ភក្តី ទទួលសិទ្ធគ្រប់គ្រង យកភាស៊ីលើផ្សារសាលាក្រៅ និងលោកសៅ សាបុណ្យ ទទួលសិទ្ធគ្រប់គ្រង យកភាស៊ីលើផ្សាព្រំថ្មី៕



# ឯកឧត្តម អ៊ី ឈាន អញ្ជើញពន្លត់ទៀនជ័យ ក្រោយអុជបំភ្លឺរយៈពេល ៣ថ្ងៃ នៃពិធីបុណ្យឯករាជ្យជាតិលើកទី៦៨



ប៉ៃលិន៖ ដូចការគ្រោងទុក នៅរសៀលថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១ ឯកឧត្តមនាយឧត្តមសេនីយ៍ អ៊ី ឈាន រដ្ឋលេខាធិការក្រសួងការពារជាតិ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តប៉ៃលិន បានអញ្ជើញពន្លត់ទៀនជ័យ ដើម្បីបញ្ចប់ពិធីបុណ្យរំឭកខួបទិវាឯករាជ្យជាតិ លើកទី៦៨ ដែលបានដុតបំភ្លឺអស់រយៈពេល ៣ថ្ងៃ នៅវិមានឯករាជ្យខេត្ត ចាប់តាំងពីថ្ងៃទី៩ ខែវិច្ឆិកា កន្លងទៅ។



នៅក្នុងពិធីពន្លត់ទៀនជ័យនៃទិវាបុណ្យឯករាជ្យជាតិនេះ ក៏មានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម សៅ សារ៉ាត់ អ្នកតំណាងរាស្ត្រមណ្ឌលប៉ៃលិន និងឯកឧត្តម ជា ចាន់ឌិន ប្រធានក្រុមប្រឹក្សាខេត្ត ព្រមទាំងថ្នាក់ដឹកនាំមន្ត្រីរាជការមន្ទីរស្ថាប័នជុំវិញខេត្ត កងកម្លាំងប្រដាប់អាវុធ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋយ៉ាងច្រើនកុះករ។

ថ្លែងក្នុងពិធីនោះដែរ ឯកឧត្តម អ៊ី ឈាន ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តប៉ៃលិន មានប្រសាសន៍លើកឡើងថា៖ ការរំលឹកបុណ្យឯករាជ្យជាតិ (០៩ វិច្ឆិកា ១៩៥៣-០៩ វិច្ឆិកា ២០២១) គឺជាទិវាប្រវត្តិសាស្ត្រដ៏ថ្លៃថ្លារបស់ប្រជាជាតិខ្មែរ ដើម្បីរំលឹកគុណូបការៈ





ដ៏ខ្ពង់ខ្ពស់បំផុត ជូនចំពោះព្រះវិញ្ញាណក្ខន្ធព្រះបរមរតនកោដ្ឋ ដែលព្រះអង្គ បានដឹកនាំការទាមទារឯករាជ្យ ពីអាណានិគមនិយមបារាំង និងរំលឹកគុណដល់វីរៈកុលបុត្រ



កុលធីតា កងកម្លាំងប្រដាប់អាវុធ នៃកងយោធពលខេមរភូមិន្ទ នៅគ្រប់ជំនាន់ ដោយបានឆ្លងកាត់នូវគ្រប់ដំណាក់កាលធំៗ ជាប្រវត្តិសាស្ត្ររបស់ប្រទេសជាតិ រួមមានការតស៊ូដណ្តើមឯករាជ្យ ការពុះពារឆ្លងកាត់ដំណាក់កាល នៃសង្គ្រាមនិងរបបប្រល័យពូជសាស្ត្រ ប៉ុលពត ជាពិសេស



លើមូលដ្ឋាន នៃជ័យជម្នះថ្ងៃ០៧ មករា ឆ្នាំ១៩៧៩ ដែលបានកសាងនូវអ្វីៗគ្រប់យ៉ាង ដូចបច្ចុប្បន្ននេះ។ ដូច្នេះ ដើម្បីបន្តនូវគំរូវីរៈភាព ដ៏ឧត្តុងឧត្តមថ្លៃថ្លានេះ សូមកម្លាំងប្រដាប់អាវុធទាំងអស់ ជាពិសេសកងយោធពលខេមរភូមិន្ទ សូមបន្តការពារមាតុភូមិ ការពារសន្តិសុខសណ្តាប់ធ្នាប់ ថែរក្សារាល់សមិទ្ធផល របស់ជាតិឲ្យគង់វង្សស្ថិតស្ថេរ



និងរួមចំណែកកសាងអភិវឌ្ឍន៍ប្រទេសជាតិឲ្យបានរីកចម្រើនរុងរឿង ក្នុងឯករាជ្យ សន្តិភាព ស្ថិរភាព និងការរួបរួមក្នុងមហាសាមគ្គីជាតិ ដ៏ទូលំទូលាយ ដោយគ្មានការកើតឡើងជាថ្មីទៀត នូវសង្គ្រាមសោកនាដកម្ម និងគ្រោះមហន្តរាយដូចអតីតកាល។



ឯកឧត្តមប្រធានក្រុមការងារ បានមានប្រសាសន៍បញ្ជាក់ថាៈ ទិវាបុណ្យឯករាជ្យជាតិ និងទិវាខួបកំណើតកងយោធពលខេមរភូមិន្ទនាពេលនេះ បានឆ្លុះបញ្ចាំង ពី

ជោគជ័យក្នុងកម្លាំងមហាសាមគ្គី របស់ប្រជាជាតិខ្មែរយើងទាំងមូល ដែលបានឆ្លងកាត់ដំណាក់កាលមួយ



ទៅដំណាក់កាលមួយប្រកបដោយភាពបត់បែន នៃដំណើរប្រវត្តិសាស្រ្ត ដ៏ស្មុគស្មាញជាច្រើន ជាពិសេសឆ្លងកាត់រយៈពេល ៦៨ឆ្នាំកន្លងមក រហូតដល់បច្ចុប្បន្ននេះ គឺនៅតែរក្សាបាននូវអត្តសញ្ញាណជាកម្លាំងប្រដាប់អាវុធ



របស់ជាតិកម្ពុជា ជាកងយោធពលខេមរភូមិន្ទដ៏អង់អាចក្លាហាន ដែលប្រសូតចេញពីប្រជាជន ដើម្បីប្រជាជន និងឆ្លើយតបទៅនឹងសំណូមពរ នៃការតស៊ូដ៏ត្រឹមត្រូវ





របស់ប្រជាជន អ្វីៗទាំងអស់ដើម្បីបម្រើ ឧត្តមប្រយោជន៍ប្រទេសជាតិ និងប្រជាជនកម្ពុជាជាដរាបតរៀងមក និងយូរអង្វែងផងដែរ។



សូមជម្រាបថា៖ កម្ពុជា បានទទួលឯករាជ្យកាលពីថ្ងៃ៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ហើយចាប់ពីពេលនោះមកកម្ពុជា បានរៀបចំទិវាបុណ្យឯករាជ្យជាតិ៩វិច្ឆិកា ជារៀងរាល់ឆ្នាំ ដើម្បីឧទ្ទិសដល់ព្រះរាជបូជនីយកិច្ចរបស់ព្រះបរមរតនកោដ្ឋ សម្តេច ព្រះនរោត្តម សីហនុ ដែលទ្រង់បានតស៊ូទាមទារឯករាជ្យពីអាណានិគមបារាំង៕



# រដ្ឋបាលខេត្តប៉ៃលិន រៀបចំសួនផ្កាចម្រុះពណ៌ នៅតំបន់ទឹកធ្លាក់អូរតាវ៉ៅដើម្បីទាក់ទាញទេសចរណ៍មកកំសាន្ត ខេត្តប៉ៃលិន





ប៉ៃលិន៖ ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២១ ឯកឧត្តម ហុក សុផល អភិបាលរងខេត្តប៉ៃលិន បានដឹកនាំមន្ទីរ ជំនាញអង្គភាពជុំវិញខេត្ត ធ្វើការរៀបចំសួនដាំផ្កាចម្រុះពណ៌ នៅតំបន់ ទឹកធ្លាក់ភ្នំខៀវអូរតាវ៉ៅ ដើម្បីលើកកម្ពស់ សោភណ្ឌភាព ក្នុងគោលបំណងទាក់ទាញភ្ញៀវ ទេសចរណ៍មកកំសាន្តឱ្យបានកាន់តែច្រើនឡើង ដែលជាកត្តាជួយជំរុញកំណើនសេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ រមណីយដ្ឋានធម្មជាតិទឹកធ្លាក់ភ្នំខៀវអូរតាវ៉ៅ ដោយចាក់បេតុងអាមេ ប្រវែងជាង ២ពាន់ម៉ែត្រ ព្រមទាំងកែរលម្អសោភ័ណភាពបន្ថែម ធ្វើសួនច្បារ ដាំផ្កាភ្ញីចម្រុះពណ៌ និងធ្វើកញ្ចុះសម្រាប់សម្រាកសម្ងៃ ដើម្បីទាក់ទាញភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ មកកំសាន្ត នាពេលបញ្ចប់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ និងបើកប្រទេសឡើងវិញ ។





ឯកឧត្តម ហុក សុផល អភិបាលរងខេត្តប៉ៃលិន បានមានប្រសាសន៍លើកឡើងថា៖ បច្ចុប្បន្នរដ្ឋបាលខេត្តប៉ៃលិន ក្រោមការដឹកនាំរបស់លោកជំទាវ បាន ស្រីមុំ ជាអភិបាលខេត្ត បានកំពុងធ្វើការស្ថាបនាផ្លូវឡើងទៅកាន់

ឯកឧត្តមអភិបាលរងខេត្ត បានមានប្រសាសន៍បញ្ជាក់ថា៖ ជាក់ស្តែងនៅថ្ងៃនេះ ឯកឧត្តមបានដឹកនាំថ្នាក់ដឹកនាំ មន្ត្រីរាជការ អង្គភាពជំនាញជុំវិញខេត្ត ធ្វើការរៀបចំសួនដាំផ្កាចម្រុះពណ៌ នៅតំបន់ទឹកធ្លាក់ភ្នំខៀវអូរតាវ៉ៅ ក្នុងគោលបំណងចង់ឱ្យមន្ត្រីរាជការ បង្ហាញពី

ចូលរួមចំណែកក្នុងការងារសង្គម និងការស្រលាញ់បរិស្ថានធម្មជាតិ ដែលជាគម្រូដ៏ល្អសម្រាប់ប្រជាពលរដ្ឋ និងទី២ គឺដើម្បីបង្កើនសាមគ្គីភាព ឯកភាព ប្រកបដោយភាពស្និតស្នាល និងការទទួលខុសត្រូវខ្ពស់។



ក្នុងឱកាសនោះផងដែរ ឯកឧត្តម ហុក សុផល ក៏បានមានប្រសាសន៍ជំរុញដល់មន្ត្រីជំនាញពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ត្រូវធ្វើការអប់រំណែនាំ និងសហការជាមួយប្រជាពលរដ្ឋឲ្យចូលរួមលើការងារថែរក្សាអនាម័យបរិស្ថាន ដោយត្រូវរួមគ្នាសំអាតនៅមុខផ្ទះ និងម្ចាស់ទីតាំងអាជីវកម្មរបស់ខ្លួនឲ្យបានជាប្រចាំជាពិសេស អាជីករលក់ដូរនៅតាមទីសាធារណៈ តាមសួនច្បារ និងតាមរម្មណីដ្ឋានទេសចរណ៍នានាក្នុងខេត្ត ត្រូវវេចខ្ចប់កាកសំណល់សំរាមឲ្យបានល្អ និងនាំយកទៅទុកដាក់ឲ្យបាន



ត្រឹមត្រូវតាមក្បួនខ្នាត គឺមិនត្រូវបោះចោលសំរាមគ្មានសណ្តាប់ធ្នាប់នៅតាមទីសាធារណៈនោះទេ ទើបយើងអាចសម្អាតអនាម័យបរិស្ថាន និងមានសោភ័ណភាពបានល្អ។



សូមបញ្ជាក់ថា៖ បច្ចុប្បន្ននេះ ផ្លូវគមនាគមន៍ទៅកាន់រមណីដ្ឋានធម្មជាតិទឹកធ្លាក់អូរតាវ៉ៅ គឺមានផ្លូវក្រាលកៅស៊ូ ១ខ្សែរស្ថាបនារួចរាល់ ១០០% ប្រភេទ DBST មានទទឹង ២០ម៉ែត្រ ប្រវែងជាង ៥គីឡូម៉ែត្រ ចាប់ពីចំនុចផ្លូវជាតិលេខ ៥៧ រហូតដល់កុងត្រូលច្រកចូលរម្មណីយដ្ឋាន និងផ្លូវបេតុងអាមេ ១ខ្សែរ មានទទឹង ៨ម៉ែត្រ ប្រវែង ២គីឡូម៉ែត្រ ដែលកំពុងស្ថាបនា បន្តពីផ្លូវក្រាលកៅស៊ូ






រហូតដល់រម្មណីយដ្ឋានតែម្តង ដើម្បីផ្តល់សេវាឱ្យកាន់តែងាយស្រួល ក្នុងការធ្វើដំណើររបស់ភ្ញៀវទេសចរណ៍ជាតិ+អន្តរជាតិ ដែលជាកត្តាជួយជំរុញកំណើនភ្ញៀវទេសចរណ៍មកកំសាន្តក្នុងខេត្តប៉ៃលិន៕

# ល្អាងភ្នំព្រះឥន្ទលក់លតជាសក្តានុពលទេសចរថ្មីរបស់ខេត្តប៉ៃលិន





ល្អាងភ្នំព្រះឥន្ទលក់លត ដែលមានទីតាំងស្ថិតក្នុងភូមិស្រះពីរតាឈាន ក្នុងឃុំអូរអណ្តូង ស្រុកសាលាក្រៅ ខេត្តប៉ៃលិន ជាល្អាងភ្នំដែលកើតឡើងពីធម្មជាតិ (បេតិកភណ្ឌវប្បធម៌ធម្មជាតិពិតៗ) ដោយមិនមានស្លាកស្នាមអ្វីបន្សល់ទុកនៅក្នុងល្អាងនោះទេ។ ល្អាងភ្នំមានសភាពធំទូលាយ អាចដាក់មនុស្សបានចន្លោះចាប់ពី ៥០ ទៅ ១០០នាក់។ ល្អាងភ្នំព្រះឥន្ទលក់លត មានភាពស្រស់ស្អាត ទាំងផ្នែកខាងក្នុងល្អាងភ្នំ និងទេសភាពនៅជុំវិញភ្នំផងដែរ។

លោក អ៊ី លីឈុន អនុប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តប៉ៃលិន បានដឹងនាំក្រុមការងារមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ចុះសិក្សាស្រាវជ្រាវពីល្អាងភ្នំព្រះឥន្ទលក់លតនេះ និងបានសន្និដ្ឋានថា៖ ល្អាងភ្នំព្រះឥន្ទលក់លត មិនមានជាប់ទាក់ទងនឹងប្រវត្តិសាស្ត្របុរាណអ្វីឡើយ។ ល្អាងភ្នំព្រះឥន្ទលក់លតនេះ ជាអំណោយផលធម្មជាតិដល់ការបង្កើតជាតំបន់ទេសចរ សម្រាប់ទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិមកលេងកំសាន្ត៕








# លោក ជំទាវ បាន ស្រីមុំ ប្រជុំដោះស្រាយទំនាស់ដីធ្លីរវាង លោក នុន ស៊ីនឿន និង ប្រជាពលរដ្ឋ ចំនួន ៨គ្រួសារ ស្ថិតនៅភូមិបឹងព្រលិត





រសៀលថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១, នៅសាលាខេត្តប៉ៃលិន, លោកជំទាវ បាន ស្រីមុំ អភិបាលនៃគណៈអភិបាលខេត្តប៉ៃលិន បានអញ្ជើញដឹកនាំកិច្ចប្រជុំជាមួយនឹងអាជ្ញាធរដែនដី មន្ទីរជំនាញពាក់ព័ន្ធ ដោះស្រាយទំនាស់ដីធ្លីរវាងលោក នុន ស៊ីនឿន និងប្រជាពលរដ្ឋចំនួន ៨គ្រួសារ នៅក្នុងភូមិបឹងព្រលិត ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន។



មានប្រសាសន៍បើកអង្គប្រជុំដោះស្រាយទំនាស់ដីធ្លីនេះ លោកជំទាវ បាន ស្រីមុំ អភិបាលនៃគណៈអភិបាលខេត្តប៉ៃលិន បានលើកឡើងថា ការដោះស្រាយទំនាស់នាពេលនេះ គឺឈរនៅលើគោលការណ៍ ឈ្នះ-ឈ្នះ ទាំងអស់គ្នា។ ដូច្នេះគ្រប់ភាគីទាំងអស់ ត្រូវមានការយោគយល់ និងលះបង់ ដើម្បីរកឃើញនូវចំណុចរួមមួយដែលទទួលយកបានទាំងអស់គ្នា។ លោកជំទាវក៏បានណែនាំដល់អាជ្ញាធរដែនដី និងមន្ទីរជំនាញដែលពាក់ព័ន្ធ



នឹងការងារដោះស្រាយទំនាស់ដីធ្លីនេះ ត្រូវឈរនៅកណ្តាល មិនត្រូវមានការលំអៀង ឬកាន់ជើងខាងណាណាមួយឡើយ។



សូមបញ្ជាក់ថា ទំនាស់ដីធ្លីនេះ បានកើតឡើង តាំងពីសម័យក្រោយសមាហរណកម្ម មកម្ល៉េះ ពោលគឺជាពេលមួយដែលប្រជាពលរដ្ឋ នាំគ្នាកាប់រាន ទន្ទ្រានយកដីព្រៃសម្រាប់ធ្វើចំការ និងធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ហើយទំនាស់នេះ ក៏ត្រូវបានដោះស្រាយជាបន្តបន្ទាប់ រហូតដល់មានការឡើងដល់កុលាកាទៀតផង។

(អត្ថបទ៖ វួច ពឿន AKP ប៉ៃលិន)











# អភិបាលខេត្តប៉ៃលិន ពិនិត្យមើលការដ្ឋានស្ថាបនាផ្លូវបេតុងអាមេ ឡើងទៅកាន់រមណីយដ្ឋានធម្មជាតិទឹកធ្លាក់អូរតាវ៉ៅ ដើម្បីផ្តល់សេវាឱ្យកាន់តែងាយស្រួលក្នុងការធ្វើដំណើររបស់ភ្ញៀវទេសចរណ៍







ប៉ៃលិន៖ ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ លោកជំទាវ បាន ស្រីមុំ អភិបាលខេត្តប៉ៃលិន អមដំណើរដោយថ្នាក់ដឹកនាំខេត្ត និងក្រុមការងារ ព្រមទាំងមន្រ្តីជំនាញពាក់ព័ន្ធ បានអញ្ជើញពិនិត្យមើលការដ្ឋានស្ថាបនាផ្លូវបេតុងអាមេ ១ខ្សែរឡើងទៅកាន់រម្មណីយ៍ដ្ឋានធម្មជាតិទឹកធ្លាក់អូរតាវ៉ៅ ស្ថិតក្នុងភូមិខ្លុង សង្កាត់អូរតាវ៉ៅ ក្រុងប៉ៃលិន ខេត្តប៉ៃលិន ដើម្បីផ្តល់សេវាឱ្យកាន់តែងាយស្រួលក្នុងការធ្វើដំណើររបស់ភ្ញៀវទេសចរណ៍ជាតិ+អន្តរជាតិ ដែលជាកត្តាជួយជំរុញកំណើនសេដ្ឋកិច្ចរបស់ខេត្តប៉ៃលិន។



លោកជំទាវ បាន ស្រីមុំ អភិបាលខេត្តប៉ៃលិន បានមានប្រសាសន៍លើកឡើងថា៖ រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំរបស់ សម្តេចតេជោ សែន គឺបានខិតខំប្រឹងប្រែងដោះស្រាយនូវរាល់ការលំបាក និងសំណូមពររបស់ប្រជាពលរដ្ឋ ព្រមទាំងបានខិតខំកសាងអភិវឌ្ឍន៍ប្រទេសជាតិឱ្យមានការរីកចម្រើនលើគ្រប់វិស័យ ជាពិសេសការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ននានាដូចជា៖



ផ្លូវ ស្ពាន សាលារៀន មន្ទីរពេទ្យ ជាដើម ហើយបច្ចុប្បន្ននេះ រដ្ឋបាលខេត្តប៉ៃលិន បានខិតខំកែលម្អហេដ្ឋារចនា

សម្ព័ន្ធសាធារណៈក្នុងខេត្ត ជាពិសេសអភិវឌ្ឍន៍តំបន់រម្មណីយដ្ឋានទេសចរណ៍នានា ឱ្យបានកាន់តែល្អឡើង ដើម្បីទាក់ទាញភ្ញៀវជាតិ និងអន្តរជាតិ មកកំសាន្តក្នុងខេត្តប៉ៃលិនយើង ឱ្យបានកាន់តែច្រើនឡើង ដែលជាកត្តាមួយចូលរួមចំណែកក្នុងការជំរុញកំណើនសេដ្ឋកិច្ចជីវភាពរបស់ប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរឡើង។



លោកជំទាវអភិបាល បានមានប្រសាសន៍បញ្ជាក់ថា៖ ដោយមើលឃើញពីសក្តានុពល នៃវិស័យទេសចរធម្មជាតិ និងដើម្បីលើកកម្ពស់សោភ័ណភាព រមណីដ្ឋានធម្មជាតិទឹកធ្លាក់អូរតាផៅ (ភ្នំខៀវប៉ៃលិន) លោកជំទាវបានណែនាំអោយយុវជន សសយក ខេត្ត សហការជាមួយមន្ត្រីជំនាញ ធ្វើការរៀបចំសណ្តាប់ធ្នាប់ អនាម័យ



និងកែរលម្អហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងរុះរើកញ្ចុះដែលពុកផុយចេញ និងដាក់ជំនួសដោយកញ្ចុះថ្មី ដែលមានរចនាបថបែបទាក់ទាញ ប្រកបដោយសុវត្ថិភាព សម្រាប់



ទទួលភ្ញៀវទេសចរណ៍ ចូលមកកម្សាន្តនៅលើទឹកដីដ៏តូចច្រឡឹងនៃខេត្តត្បូងពេជ្រ មួយនេះ។



ឱកាសនោះផងដែរ លោកជំទាវ បាន ស្រីមុំ ក៏បានប្រសាសន៍សំណូមពរដល់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរណ៍ទាំងអស់ ដែលមកកំសាន្តតាមរម្មណីយដ្ឋាននានាក្នុងខេត្តប៉ៃលិន ត្រូវរួមគ្នាសំអាតអនាម័យបរិស្ថាន ដោយត្រូវវេចខ្ចប់កាកសំណល់សំរាមឲ្យបានល្អ និងនាំយកទៅទុកដាក់ឲ្យបានត្រឹមត្រូវតាមក្បួនខ្នាត ជៀសវាង





ការបោះចោលសំរាមគ្មានសណ្តាប់ធ្នាប់ ដែលធ្វើឱ្យប៉ះពាល់ដល់សោភ័ណភាព និងអនាម័យសាធារណៈ។





ហើយបច្ចុប្បន្នអាជ្ញាធរខេត្ត កំពុងធ្វើការស្ថាបនាផ្លូវបេតុងអាមេ ប្រវែងជាង ៣គីឡូម៉ែត្រ ឡើងទៅកាន់រម្មណីយដ្ឋានទឹកធ្លាក់អូរតាវៅនេះ ដើម្បីសម្រួលដល់ការធ្វើដំណើររបស់ភ្ញៀវទេសចរណ៍ជាតិ+អន្តរជាតិ៕



សូមបញ្ជាក់ថា៖ រម្មណីយដ្ឋាន ទឹកធ្លាក់អូរតាវៅ ជារម្មណីយដ្ឋានធម្មជាតិល្បីជាងគេ នៅក្នុងខេត្តប៉ៃលិន ដែលមានទឹកធ្លាក់រហូតដល់ ៩ជាន់ និងមានចម្ងាយចេញពីផ្លូវជាតិលេខ៥៧ ប្រមាណជាង ៧គីឡូម៉ែត្រ ស្ថិតនៅក្នុងភូមិខ្លុង សង្កាត់អូរតាវៅ ក្រុងប៉ៃលិន ខេត្តប៉ៃលិន







# អភិបាលខេត្តប៉ៃលិន ពិនិត្យមើលការដ្ឋានស្ថាបនាផ្លូវក្រាលកៅស៊ូ ប្រភេទ DBST ២ខ្សែ ប្រវែង ៥៤គីឡូម៉ែត្រ



ប៉ៃលិន៖ ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២១ លោកជំទាវ បាន ស្រីមុំ អភិបាលខេត្តប៉ៃលិន អមដំណើរដោយថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ ព្រមទាំងក្រុមការងារ បានអញ្ជើញចុះពិនិត្យមើលការដ្ឋានស្ថាបនាផ្លូវក្រាលកៅស៊ូ ប្រភេទ DBST ចំនួន ២ខ្សែ ប្រវែង ៥៤គីឡូម៉ែត្រ ដោយខ្សែទី១ ភ្ជាប់ពីចំណុចបំបែកផ្លូវជាតិលេខ៥៩ ក្នុងភូមិទំនប់ រហូតដល់ចំណុចផ្សារឃៃរ ក្នុងឃុំស្ទឹងត្រង់ ស្រុកសាលាក្រៅ និងខ្សែទី២ ចាប់ពីផ្សារឃៃរ ក្នុងភូមិដីស ឃុំស្ទឹងត្រង់ ស្រុកសាលាក្រៅ រហូតភ្ជាប់នឹងផ្លូវជាតិលេខ៥៧ ត្រង់ចំណុចបំបែក (អូរស្នួស្តី) ក្នុងភូមិប៉ាងរលឹម សង្កាត់អូរតាវ៉ៅ ក្រុងប៉ៃលិន ខេត្តប៉ៃលិន។




លោកជំទាវ បាន ស្រីមុំ អភិបាលខេត្តប៉ៃលិន បានមានប្រសាសន៍លើកឡើងថា៖ ផ្លូវ ស្ពាន គឺជាសរសៃឈាមនៃសេដ្ឋកិច្ចជាតិ និងគ្រួសារ ដូច្នេះមានផ្លូវ គឺមានក្តីសង្ឃឹម ហើយការធ្វើផ្លូវ ១ខ្សែនេះ គឺពិតជាបានបំពេញនូវសេចក្តីត្រូវការរបស់បងប្អូនប្រជាពលរដ្ឋ ងាយស្រួលក្នុងការធ្វើចរាចរណ៍ ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ជាពិសេសបានផ្តល់នូវភាពងាយស្រួលដល់សិស្សាសិស្សបានធ្វើដំណើរទៅសាលារៀន។



លោកជំទាវអភិបាលខេត្ត បានមានប្រសាសន៍បញ្ជាក់ថា៖ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់



សម្តេចតេជោ សែន គឺបានខិតខំប្រឹងប្រែងដោះស្រាយនូវរាល់ការលំបាក និងសំណូមពររបស់ប្រជាពលរដ្ឋ ព្រមទាំងបានខិតខំកសាងអភិវឌ្ឍន៍ប្រទេសជាតិឱ្យមានការរីកចម្រើនលើគ្រប់វិស័យ ជាពិសេសការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ននានា ដូចជា៖ ផ្លូវ ស្ពាន សាលារៀន មន្ទីរពេទ្យ ជាដើម។



ក្នុងឱកាសនោះផងដែរ លោកជំទាវ បាន ស្រីមុំ ក៏បានផ្តាំផ្ញើរដល់បងប្អូនប្រជាពលរដ្ឋដែលប្រើប្រាស់ផ្លូវនេះទាំងអស់ មេត្តាផ្តល់កិច្ចសហការ និងសម្របសម្រួលនូវផលប៉ះពាល់នានា ក្នុងការស្ថាបនាផ្លូវនេះឱ្យបានឆាប់រហ័សទៅតាមផែនការគ្រោងទុក ១០០% ព្រមទាំងចូលរួមជួយថែរក្សា ដើម្បីធានាឱ្យការប្រើប្រាស់បានយូរអង្វែង។

សូមបញ្ជាក់ថា៖ ផ្លូវក្រាលកៅស៊ូប្រភេទ DBST ទាំង ២ខ្សែរ ដែលកំពុងស្ថាបនានេះ មានប្រវែងសរុប



៥៤គីឡូម៉ែត្រ ដោយខ្សែរទី១ មានប្រវែង ២៤គីឡូម៉ែត្រ ទទឹង ៨ម៉ែត្រ និងខ្សែរទី២ មានប្រវែង ៣០គីឡូម៉ែត្រ ទទឹង ៦ម៉ែត្រ និងមានដាក់ប្រព័ន្ធលូជាច្រើនកន្លែង



បន្ថែមទៀត ដើម្បីបញ្ជាសបញ្ហាស្ទះទឹក ដែលបណ្តាលអោយលិចផ្លូវ ឬផ្ទះប្រជាពលរដ្ឋ ពេលមានករណីជំនន់ទឹកភ្លៀងម្តងៗ៕



# ក្រុមការងារគណបក្សប្រជាជនកម្ពុជាចុះជួយសង្កាត់ទួលល្វារៀបចំការបោះឆ្នោតជ្រើសរើសបេក្ខជនសម្រាប់ឈរឈ្មោះជាក្រុមប្រឹក្សាសង្កាត់ សម្រាប់ការប្រឡងប្រជែងក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ នាឆ្នាំ២០២២ខាងមុខ




ព្រឹកថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២១ ឯកឧត្តម គោស៊ុំ ប៊ុនសឿត ប្រធានក្រុមការងារគណបក្សប្រជាជនកម្ពុជាចុះជួយសង្កាត់ទួលល្វា បានដឹកនាំការរៀបចំការបោះឆ្នោតជ្រើសរើសបេក្ខជនសម្រាប់ឈរឈ្មោះជាក្រុមប្រឹក្សាសង្កាត់ សម្រាប់ការប្រឡងប្រជែងក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់- នាឆ្នាំ២០២២ខាងមុខ។ សមាសភាពដែលបានអញ្ជើញចូលរួមក្នុងការបោះឆ្នោតនេះរួមមាន ប្រធាន អនុប្រធាន និងសមាជិកក្រុមការងារគណបក្សប្រជាជនកម្ពុជាចុះជួយសង្កាត់ទួលល្វា ក្រុមប្រឹក្សាសង្កាត់ លោកមេភូមិ សមាជិកភូមិ និងយុវជនគណបក្សសង្កាត់ផងដែរ។



ឯកឧត្តម គោស៊ុំ ប៊ុនសឿត ប្រធានក្រុមការងារគណបក្សប្រជាជនកម្ពុជាចុះជួយសង្កាត់ទួលល្វាបានមានប្រសាសន៍ថា ការរៀបចំការបោះឆ្នោតនេះ គឺធ្វើឡើងតាមគោលនយោបាយរបស់គណបក្សប្រជាជនកម្ពុជា ដើម្បីជ្រើសរើសបេក្ខជនរបស់គណបក្សដែលមានសមត្ថភាព និងការគាំទ្រច្រើនពីសំណាក់ថ្នាក់ដឹកនាំបក្ស ក្រុមការងារចុះជួយសង្កាត់ និងប្រជាពលរដ្ឋមូលដ្ឋាន ដើម្បី



បានឈរឈ្មោះជាក្រុមប្រឹក្សាសង្កាត់ទួលល្វា សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ដែលនឹងប្រព្រឹត្តទៅក្នុងឆ្នាំ២០២២ ខាងមុខនេះ។ ឯកឧត្តមបានមាន



ប្រសាសន៍បន្តថា ការបោះឆ្នោតជ្រើសរើសបេក្ខជនរបស់គណបក្ស សម្រាប់ឈរឈ្មោះជាក្រុមប្រឹក្សាសង្កាត់នេះ គឺធ្វើឡើងដោយយុត្តិធម៌ មានតម្លាភាព និងប្រជាធិបតេយ្យ។ បេក្ខជនដែលទទួលបាននូវសំឡេងគាំទ្រច្រើន នឹងមានសិទ្ធិដើម្បីឈរឈ្មោះជាក្រុមប្រឹក្សាសង្កាត់ទួលល្វា



សម្រាប់ការប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នាឆ្នាំ២០២២ ខាងមុខនេះ។ ចំណែកអ្នកដែលមិនទទួលបាននូវសំឡេងគាំទ្រច្រើន ក៏មិនត្រូវអាក់អន់ស្រពន់ចិត្តអ្វីដែរ តែត្រូវខិតខំប្រឹងប្រែងធ្វើ





ការងារ និងកសាងប្រជាប្រិយភាពនៅក្នុងស្រទាប់ថ្នាក់ដឹកនាំ និងមហាជន ប្រជាជន។



ការបោះឆ្នោតនេះបានប្រព្រឹត្តទៅអស់រយៈពេលពេញមួយព្រឹក ហើយសន្លឹកឆ្នោតដែលបានបោះរួច ត្រូវបានវេចខ្ចប់យ៉ាងត្រឹមត្រូវ បញ្ជូនទៅរាប់នៅទីស្នាក់ការគណបក្សប្រជាជនកម្ពុជាខេត្តប៉ៃលិន៕

(អត្ថបទ: វួច ពឿន AKP)



# អភិបាលខេត្តប៉ៃលិន កាត់ស្រោមវិញ្ញាសាប្រឡងជ្រើសរើសក្របខ័ណ្ឌមន្រ្តីរាជការស៊ីវិល បម្រើការនៅរដ្ឋបាលខេត្ត សម្រាប់ឆ្នាំ២០២១





ប៉ៃលិន៖ នៅមណ្ឌលប្រឡង វិទ្យាល័យ ហ៊ុន សែន ទេពនិម្មិត្តប៉ៃលិន ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ លោកជំទាវ បាន ស្រីមុំ អភិបាល នៃគណៈអភិបាលខេត្តប៉ៃលិន បានអញ្ជើញកាត់ស្រោមវិញ្ញាសាប្រឡងជ្រើសរើសមន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌថ្មី ឱ្យចូលបម្រើការងារនៅរដ្ឋបាលខេត្តប៉ៃលិន ឆ្នាំ២០២១ ក្រោមការយកចិត្តទុកដាក់ខ្ពស់ ចំពោះបេក្ខជន និងអនុរក្ស ក្នុងមណ្ឌលប្រឡងទាំងអស់ ត្រូវមានកាតចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ទើបអនុញ្ញាតឱ្យចូលក្នុងមណ្ឌលប្រឡង ជាពិសេសការអនុវត្តន៍វិធានការសុខាភិបាល និងវិធានការ ៣ការពារ ៣កុំ  របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ដើម្បីសហគមន៍គ្មានការចម្លងជំងឺកូវីដ-១៩។



ថ្លែងក្នុងឱកាសនោះដែរ លោកជំទាវ បាន ស្រីមុំ អភិបាលខេត្តប៉ៃលិន បានមានប្រសាសន៍លើកឡើងថា៖ ការកាត់ស្រោមវិញ្ញាសារជូនដល់បេក្ខជនប្រឡងនាពេលនេះ គឺ បានបង្ហាញ និងពិនិត្យអំពីភាពបិទជិតដោយស្កុត និងត្រាស្រោមប្រធានវិញ្ញាសារ នៅចំពោះមុខបេក្ខជន និង គណៈកម្មការមេប្រយោគ ចូលរួមជាសាក្សី ដើម្បីបញ្ជាក់ថា វិញ្ញាសានេះពិតជាពុំមានរហែក ឬបែកធ្លាយពិតប្រាកដមែន ដើម្បីធានាបានថា ការប្រឡងគឺប្រព្រឹត្តទៅដោយគោរពតាមគោលការណ៍ច្បាប់ យុត្តិធម៌ តម្លាភាព និងលទ្ធផលទទួលយកបានទាំងអស់គ្នា។





លោកជំទាវអភិបាលខេត្ត ក៏បានមានប្រសាសន៍ណែនាំបន្ថែម ដល់បេក្ខជន បេក្ខនារី សូមយកចិត្តទុកដាក់ប្រឹងប្រែងបញ្ចេញអោយអស់សមត្ថភាព និងចំណេះដឹងដែលខ្លួនមាន ព្រមទាំងគោរពតាមបទបញ្ជាផ្ទៃក្នុងនៅពេលប្រឡងឱ្យបានល្អ ដើម្បីថែរក្សាសន្តិសុខសុវត្ថិភាព និងរក្សាសណ្តាប់ធ្នាប់របៀបរៀបរយពេលប្រឡង



ក្នុងការចូលរួមប្រឡងប្រជែងជ្រើសរើសក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលថ្មី ដែលជាមន្ត្រីបន្តវេន ជាទំពាំងស្នងឬស្សី ដើម្បីចូលរួមបំរើជាតិ និងប្រជាជន។





បើតាមការបញ្ជាក់របស់ ឯកឧត្តម ហុក សុផល អភិបាលរងខេត្ត និងជាប្រធានគណៈកម្មាធិការមេប្រយោគ ប្រចាំមណ្ឌលប្រឡង បានឲ្យដឹងថា៖ បេក្ខជនដែលបានដាក់ពាក្យប្រឡង ក្នុងក្របខណ្ឌមន្ត្រីរាជការស៊ីវិលរបស់រដ្ឋបាលខេត្តប៉ៃលិននេះ មានចំនួន ៤៤អង្គ/នាក់ ស្រី ២១នាក់ មាន ០១មណ្ឌលប្រឡង ស្មើនឹង ០៤បន្ទប់









ហើយការប្រឡងនេះត្រូវបានប្រព្រឹត្តទៅតែរយៈពេលមួយព្រឹកប៉ុណ្ណោះ លើពីរក្របខ័ណ្ឌរួមមាន៖ ១-ក្របខ័ណ្ឌមន្ត្រីរាជការជាន់ខ្ពស់ ២-ក្របខ័ណ្ឌមន្ត្រីរាជមន្ត្រីក្រមការ ដោយប្រឡងលើវិញ្ញាសារចំនួន០២គឺ៖ វិញ្ញាសារជំនាញឯកទេស និងភាសាអង់គ្លេស៕





# សាខាកាកបាទក្រហមកម្ពុជាខេត្តប៉ៃលិន សហការជាមួយមន្ទីរសុខាភិបាល និងមន្ទីរព័ត៌មានខេត្តប៉ៃលិន បានផ្សព្វផ្សាយ ស្តីពីការបង្ការទប់ស្កាត់ជំងឺកូវីដ-១៩ តាមវិទ្យុជាតិ FM 90.5 Mhz ខេត្តប៉ៃលិន











នៅថ្ងៃចន្ទ ១០រោច ខែកក្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១ ដោយមានការយកចិត្តទុកដាក់គិតគូរខ្ពស់អំពីសុខុមាលភាពរបស់ប្រជាពលរដ្ឋក្នុងការបង្ការ ការពារជំងឺឆ្លងកូវីដ-១៩ ពីសំណាក់ សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា, សាខាកាកបាទក្រហមកម្ពុជា ខេត្តប៉ៃលិន ដែលមាន លោកជំទាវបណ្ឌិត បាន ស្រីមុំ ប្រធានគណៈកម្មាធិការសាខា និងមានការឧបត្ថម្ភ



គាំទ្រដោយគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ (ICRC) សាខាកាកបាទក្រហមកម្ពុជាខេត្តប៉ៃលិន សហការជាមួយ វិទ្យុជាតិ FM90.5MHz បានរៀបចំផ្សាយបន្តផ្ទាល់ ពីកិច្ចសម្ភាសន៍ជាមួយវាគ្មិនតាមរលកវិទ្យុជាតិខេត្តប៉ៃលិន ក្រោមប្រធានបទ(ការពិគ្រោះយោបល់អំពីកូវីដ-១៩) ដែលកម្មវិធីនេះចាប់ផ្តើមពីម៉ោង១:០០ ដល់ម៉ោង ២:០០ នាទីរសៀល និងមានការអញ្ជើញចូលរួមសម្របសម្រួលពីវាគ្មិន៖១. លោកវេជ្ជបណ្ឌិត យក់ សុវណ្ណ អនុប្រធានមន្ទីរសុខាភិបាល ២. កញ្ញា អាន់ លីណា មន្ត្រីប្រតិបត្តិសាខា។



ការរៀបចំកម្មវិធីនេះឡើង ក្នុងគោលបំណង ចូលរួមចំណែក ជាមួយរាជរដ្ឋាភិបាល ដើម្បីអោយប្រជាពលរដ្ឋទូទៅ បានយល់ដឹងអំពីការរស់នៅតាមបែបគន្លងថ្មី និងទទួលខុសត្រូវ ក្នុងការទប់ស្កាត់ ការចម្លងវីរុសកូវីដ-១៩ អោយមានប្រសិទ្ធភាពខ្ពស់ ៕

# មន្ទីរអភិវឌ្ឍន៍ជនបទខេត្តប៉ៃលិន ប្រារព្ធទិវាជាតិលើកកម្ពស់អនាម័យជនបទ ១៣ វិច្ឆិកា លើកទី១២ ក្រោមប្រធានបទ (គុណតម្លៃនៃការអនុវត្តន៍អនាម័យនិងការសំអាត )



ព្រឹកថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តប៉ៃលិន បានប្រារព្ធទិវាជាតិលើកកម្ពស់អនាម័យជនបទ ១៣ វិច្ឆិកា លើកទី១២ សម្រាប់ឆ្នាំ២០២១ ក្រោមប្រធានបទ" គុណតម្លៃនៃការអនុវត្តន៍អនាម័យនិងការសំអាត "។ ទិវានេះបានធ្វើឡើងនៅក្នុងបរិវេណសាលាបឋមសិក្សាសខេងអូរតាវៅ ក្រោមអធិបតីភាពលោក ហែម ឬទ្ធី អភិបាលរងខេត្តប៉ៃលិន និងជាតំណាងដ៏ខ្ពង់ខ្ពស់លោកជំទាវ បាន ស្រីមុំ អភិបាលខេត្តប៉ៃលិន ព្រមទាំងមានការអញ្ជើញចូលរួមពីសំណាក់លោកប្រធាន អនុប្រធានមន្ទីរ ស្ថាប័នជំនាញជុំវិញខេត្ត អាជ្ញាធរមូលដ្ឋាន អង្គការសង្គមស៊ីវិល ប្រជាពលរដ្ឋ លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្សជាច្រើននាក់ផងដែរ ។



បន្ទាប់ពីអានសាលិខិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជារួចមក លោក ហែម ឬទ្ធី អភិបាលរងខេត្តប៉ៃលិន បានមានប្រសាសន៍សំណេះសំណាលជាមួយសិស្សានុសិស្សនិងបងប្អូនប្រជាពលរដ្ឋដោយបានលើកឡើងថា៖ ការរៀបចំប្រារព្ធទិវាអនាម័យជនបទនាពេលនេះ ក្នុងគោលបំណងបន្តជម្រុញ និងផ្សព្វផ្សាយ បំផុស





ការយល់ដឹងបន្ថែមទៀត ពីសារៈសំខាន់នៃការធ្វើអនាម័យក្នុងរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ដែលជាមូលដ្ឋានសំខាន់មួយ នៃការលើកកំពស់សុខុមាលភាព និងសេដ្ឋកិច្ចគ្រួសារ។



លោកអភិបាលរងខេត្ត បានប្រសាសន៍បន្តថាៈ ការរស់នៅដោយមានអនាម័យ គឺជាកត្តាចាំបាច់សម្រាប់មនុស្សគ្រប់រូប ដើម្បីសុខភាពល្អ ជៀសផុតពីជម្ងឺតម្កាត់ផ្សេងៗ។ ក្បួនអនាម័យទាំងនោះ រួមមានៈ ការហូបស្អាត ពិសារទឹកឆ្អិន ការលាងសម្អាតដៃនឹងសាប៊ូ ការបន្ទោរបង់





ក្នុងបង្គន់អនាម័យ ការសម្អាតបរិស្ថានជុំវិញផ្ទះ ការសម្រាកសម្រានក្នុងមុងជាដើម។លោក ហែម ឬទ្ធី អភិបាលរងខេត្ត ក៏បានណែនាំដល់មន្ទីរ អង្គភាពពាក់ព័ន្ធនានា ជាពិសេសមន្ទីរអភិវឌ្ឍនជនបទ ត្រូវបន្តយកចិត្តទុកដាក់ផ្សព្វផ្សាយ បំផុសការយល់ដឹង អំពីអនាម័យជនបទ ជាពិសេសនៅតំបន់ទីជនបទដាច់ស្រយ៉ាល។

នៅក្នុងឱកាសនោះផងដែរ លោកអភិបាលរងខេត្ត ក៏បានមានប្រសាសន៍ផ្តាំផ្ញើរដល់បងប្អូនប្រជាពលរដ្ឋ សិស្សានុសិស្សត្រូវថែរក្សាសុខភាពអោយបានល្អ ព្រោះរដូវរងារចាប់ផ្តើមមកដល់ជាបណ្តើរៗហើយ ជា



ពិសេសត្រូវអនុវត្តន៍នូវវិធានការ ៣កុំ ៣ការពារទាំងអស់គ្នាដើម្បីជៀសផុតពីជម្ងឺកូវីដ-១៩ ហើយអរគុណនូវសន្តិភាពក្រោមនយោបាយឈ្នះៗរបស់សម្តេចតេជោហ៊ុន សែន ទើបយើងមានថ្ងៃនេះឡើង។





សូមបញ្ជាក់ថា៖ បើតាមរបាយការណ៍របស់លោក ហ៊ត ឬទ្ធី ប្រធានមន្ទីរអភិវឌ្ឍនជនបទខេត្តបានដឹងថា ផែនការយុទ្ធសាស្ត្រជាតិស្តីពី វិស័យសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ដំណាក់កាលទី១ ឆ្នាំ២០១៤-២០១៨ បានកំណត់គោលដៅ៦០% និងផែនការ សកម្មភាពជាតិ និងខេត្តដំណាក់កាលទី២ ឆ្នាំ២០១៩-២០២៣







បានកំណត់គោលដៅ៩០% ។ ដោយឡែកខេត្តប៉ៃលិន គិតមកដល់ត្រឹមត្រីមាសទី៣ ឆ្នាំ២០២១ នេះ ប្រជាពលរដ្ឋចំនួន ១២,០៦៣ខ្នងផ្ទះ មានបង្គន់អនាម័យកែលម្អប្រើប្រាស់ស្មើ ៧៥.៤% បើធៀបនឹងឆ្នាំ២០២០ គឺកើនឡើងបានចំនួន ៤៦៩ខ្នងផ្ទះ ស្មើ ២.៤%៕









# រដ្ឋបាលខេត្តប៉ៃលិនជួបសំណេះសំណាលជាមួយអង្គការ សាម៉ារីតាន់ភឹស ស្តីពីអនាម័យ អប់រំ និងទឹកស្អាត ដើម្បីលើកកម្ពស់អនាម័យ និងទឹកស្អាតតាមសាលារៀនព្រមទាំងសហគមន៍អោយមានភាពល្អប្រសើរក្នុងឆ្នាំ ២០២២





រសៀលថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ២០២១ នៅសាលាខេត្តប៉ៃលិន លោក ហែម ឬទ្ធី អភិបាលរងខេត្ត បានជួបសំណេះសំណាលជាមួយលោក Berry Graham Jessen នាយក អង្គការសាម៉ារីតាន់ភឹស (Samaritan´s Purse) ប្រចាំនៅកម្ពុជា ស្តីពីគម្រោង អនាម័យ និងទឹកស្អាតតាមសាលារៀនដើម្បីលើកកម្ពស់សុខមាលភាពសម្រាប់កុមារនិងបងប្អូនប្រជាពលរដ្ឋនៅទូទាំងខេត្តប៉ៃលិន ។ ដែលពិធីនេះមានការចូលរួមពីលោកអភិបាលរងក្រុង-ស្រុក លោកប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត និងលោកអនុប្រធានមន្ទីរអប់រំផងដែរ។



លោក ប៊ីរី ហ្គ្រាហាំ ជេសសាន់ ( Berry Graham Jessen ) នាយកអង្គការសាម៉ារីតាន់ភឹស (Samaritan´s Purse) ប្រចាំនៅកម្ពុជា បានថ្លែងថា៖ ដោយមើលឃើញពីការអភិវឌ្ឍន៍និងសក្តានុពលខេត្តប៉ៃលិន ដូច្នេះទើប អង្គការសាម៉ារីតាន់ភឹស មានគម្រោងលើអនាម័យ អប់រំ និងទឹកស្អាត តាមសាលារៀន សហគមន៍ ដើម្បីធ្វើយ៉ាងណាលើកកម្ពស់សុខមាលភាពរបស់កុមារអោយបានល្អប្រសើរ ។ ហើយអង្គការធ្លាប់ប្រតិបត្តិ



ការគម្រោងជោគជ័យនៅខេត្តមួយចំនួនដូចជា ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងឧត្តរមានជ័យ ដូចនេះ ហើយនៅក្នុងឆ្នាំ ២០២២ គឺអង្គការមានគម្រោងអនាម័យ អប់រំ ទឹកស្អាត ដោយត្រូវការកិច្ចសហការចូលរួមគាំទ្រពីថ្នាក់ដឹកនាំខេត្ត មន្ទីរជំនាញពាក់ព័ន្ធ ជាពិសេសអាជ្ញាធ

រមូលដ្ឋាន ដើម្បីធ្វើយ៉ាងណាអោយមានភាពរលូន និងល្អប្រសើរ ជាពិសេសខេត្តប៉ៃលិនជាខេត្តមួយដែលសន្តិភាពក្រោយគេ តែមានការរីកចម្រើនលើគ្រប់វិស័យគួរអោយកោតសសើរ ដែលនេះកាន់តែធ្វើអោយអង្គការសាម៉ារីតាន់ភឹស មានភាពកក់ក្ដៅក្នុងការអនុវត្តន៍គម្រោងជួយខេត្តប៉ៃលិន។



លោក ហៃម ឬទ្ធី អភិបាលរងខេត្ត តំណាងដ៏ខ្ពង់ខ្ពស់របស់លោកជំទាវ បាន ស្រីមុំ អភិបាលនៃគណៈអភិបាលខេត្តប៉ៃលិន បានមានប្រសាសន៍ថា៖ រដ្ឋបាលខេត្តប៉ៃលិនពិតជាមានក្ដីសោមនស្សរីករាយក្រៃលែង ដែលអង្គការសាម៉ារីតាន់ភឹស បានមានចំណាប់អារម្មណ៍លើខេត្តប៉ៃលិន សម្រាប់គម្រោង អនាម័យ អប់រំ និងទឹកស្អាត នៅខេត្តប៉ៃលិន ជាពិសេសស្រុកសាលាក្រៅតែម្ដង ដែលគម្រោងនេះគឺជាការលើកកម្ពស់សហគមន៍មិនអាចកាត់ថ្លៃបាននោះឡើយ ហើយវាជាការចូលរួមចំណែកដ៏ធំមួយក្នុងការលើកកម្ពស់សុខមាលភាពសិស្សានុសិស្ស



និងបងប្អូនប្រជាពលរដ្ឋយើងក្នុងបរិបទកូវីដ-១៩ ផងដែរ។ ជាមួយគ្នានោះ លោកអភិបាលរងខេត្ត បានបញ្ជាក់ថា សូមអោយមន្ទីរជំនាញពាក់ព័ន្ធ ជាពិសេសអាជ្ញាធរក្រុងស្រុកត្រូវមានកិច្ចសហការល្អជាមួយអង្គការសាម៉ារីតាន់ភឹសដើម្បីធ្វើយ៉ាងណាអោយមានភាពរលូននិងជួយជ្រោមជ្រែងប្រកបដោយឆន្ទៈ ការទទួលខុសត្រូវ និងសមូហភាព ដើម្បីអោយគម្រោងមួយនេះអនុវត្តន៍ជោគជ័យតាមការគ្រោងទុក។



សូមបញ្ជាក់ថា៖ អង្គការ សាម៉ារីតាន់ភឹស បានចាប់ដំណើការនៅប្រទេសកម្ពុជា ក្នុងឆ្នាំ២០០៣ ដោយអនុវត្តលើវិស័យ ទឹកស្អាត និងអនាម័យ ,សុខភាពនិងអាហាររូបត្ថម្ភ កសិកម្មនិងការអភិវឌ្ឍមុខរបរចិញ្ចឹមជីវិត , ការអប់រំ និងកម្មវិធីចំណាកស្រុកដោយសុវត្ថិភាព។ ហើយក្នុងឆ្នាំ២០២២ខាងមុខនេះ អង្គការមានកម្មវិធីអនុវត្តនៅខេត្តប៉ៃលិន លើវិស័យអនាម័យ អប់រំ និងទឹកស្អាត ផងដែរក្នុងនោះរួមាន៖ ស្រុកសាលាក្រៅមាន១៦សាលា និងក្រុងប៉ៃលិនមាន ២សាលា៕

